ក

# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៤-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១១១ ស្តីពី ការកែសម្រួលមាត្រា ៤ មាត្រា ១០ មាត្រា ១១ មាត្រា ១២ មាត្រា ១៤ មាត្រា ១៧ និងមាត្រា ២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា ១៥៩៥

០៤-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១១២ ស្តីពី ការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ០៧ រូប ១៥៩៩

១១-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១២០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លីវនី ហ្គីល** (LIVNI GIL) ជនជាតិអ៊ីស្រាអែល សញ្ជាតិអាមេរិក កើតនៅប្រទេសអ៊ីស្រាអែល ១៦០១

១១-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១២២ ស្តីពី ការតម្លើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ១៦០២

១២-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១២៦ ស្តីពី តែងតាំងឯកឧត្តម **ឌុន លាន** ជា **អគ្គនាយក** នៃអគ្គនាយកដ្ឋានថាមពល ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ១៦០៤

១២-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១២៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ១៦០៥


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១០-៣-២០០៥ -អនុក្រឹត្យលេខ ៤៤ អនក្រ.បក ស្តីពី ការកែសំរួលខ្លឹមសារមាត្រា ៥ ជំពូក ២ ផ្នែកទី ១ នៃអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ១៦០៧

១០-៣-២០០៥ -អនុក្រឹត្យលេខ ៤៥ អនក្រ.បក ស្តីពី ការផ្ទេរគណទានថវិកា ១៦០៩

១០-៣-២០០៥ -អនុក្រឹត្យលេខ ៤៦ អនក្រ.បក ស្តីពី ការបង្កើតស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប៉ូឡូញ ១៦១១

១០-៣-២០០៥ -អនុក្រឹត្យលេខ ២៧៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៦១២

១០-៣-២០០៥ -អនុក្រឹត្យលេខ ២៧៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៦១៤

១០-៣-២០០៥ -អនុក្រឹត្យលេខ ២៧៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៦១៥

១០-៣-២០០៥ -អនុក្រឹត្យលេខ ២៨០ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៦១៦

១០-៣-២០០៥ -អនុក្រឹត្យលេខ ២៨១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៦១៧

១០-៣-២០០៥ -អនុក្រឹត្យលេខ ២៨២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៦១៨

១០-៣-២០០៥ -អនុក្រឹត្យលេខ ២៨៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៦២០

១០-៣-២០០៥ -អនុក្រឹត្យលេខ ២៨៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៦២២

១១-៣-២០០៥ -អនុក្រឹត្យលេខ ២៨៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៦២៣

១១-៣-២០០៥ -អនុក្រឹត្យលេខ ២៨៦ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៦២៥

១១-៣-២០០៥ -អនុក្រឹត្យលេខ ២៨៧ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៦២៦

១១-៣-២០០៥ -អនុក្រឹត្យលេខ ២៨៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៦២៧

១៥-៣-២០០៥ -អនុក្រឹត្យលេខ ២៨៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៦២៨

១៥-៣-២០០៥ -អនុក្រឹត្យលេខ ២៩០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៦៣០

១៥-៣-២០០៥ -អនុក្រឹត្យលេខ ២៩១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៦៣២


## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០១-៣-២០០៥ -លិខិតលេខ ៤៨៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ជី ពៅ អ៊ីមផត អិចផត** ១៦៣៣

០១-៣-២០០៥ -លិខិតលេខ ៤៨៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ឆាង ឈិន អិចផត អេន អ៊ីមផត** ១៦៣៥

០១-៣-២០០៥ -លិខិតលេខ ៤៩១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អេស ឌី ស៊ីលូសិន តិធីអ៊ី អិលធីឌី** ១៦៣៧

០១-៣-២០០៥ -លិខិតលេខ ៤៩២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេស អ៊ី អឺតែលែ** ១៦៣៩

០១-៣-២០០៥ -លិខិតលេខ ៤៩៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ុ យូ អេស គ្រុប (ខេមបូឌា)** ១៦៤០

០១-៣-២០០៥ -លិខិតលេខ ៤៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់សហគ្រាស
**ហ៊ួរ តំញ** ១៦៤២

០១-៣-២០០៥ -លិខិតលេខ ៤៩៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់សហគ្រាស
**អាយតីតី អ៊ែតទើថាយស៊ុខ** ១៦៤៣

០២-៣-២០០៥ -លិខិតលេខ ៤៩៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**មីតដល ថេ អិលធីឌី** ១៦៤៤

០២-៣-២០០៥ -លិខិតលេខ ៤៩៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប៊ីក ថេ អិលធីឌី** ១៦៤៥

០២-៣-២០០៥ -លិខិតលេខ ៤៩៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់សហគ្រាស
**អង្គរ ថោន** ១៦៤៦

០២-៣-២០០៥ -លិខិតលេខ ៤៩៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់សហគ្រាស
**ម៉េង វ៉ាឌី** ១៦៤៧

០២-៣-២០០៥ -លិខិតលេខ ៥០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គ្រាក់ ហ្វ្រេច ស៊ីធីស ខូ អិលធីឌី** ១៦៤៨

០២-៣-២០០៥ -លិខិតលេខ ៥០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**(ខេមបូឌា) ស៊ុនធីច ឡាមេន ម៉េនូហ្វេកឈ័រីង** ១៦៥០

០២-៣-២០០៥ -លិខិតលេខ ៥១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ដុង យ៉ាង ចាង៉ុង អិចផ្លូរេសិន** ១៦៥១

០២-៣-២០០៥ -លិខិតលេខ ៥១៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ែរាល អ៊ែកឃ្វីបហ្វ្រីស៊ិន គ្រុប អ៊ីន** ១៦៥៣

០២-៣-២០០៥ -លិខិតលេខ ៥០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ចេនឡា ត្រាខ័រ** ១៦៥៥

០៤-៣-២០០៥ -លិខិតលេខ ៥១៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេស អិល ឃ្លាមេន ប្រូសេសស៊ីង (ខេមបូឌា)** ១៦៥៧

០៤-៣-២០០៥ -លិខិតលេខ ៥២០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប៊ូលី** ១៦៥៨

០៤-៣-២០០៥ -លិខិតលេខ ៥២៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ដាតា វើលដ៍** ១៦៦០

០៤-៣-២០០៥ -លិខិតលេខ ៥២៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គូចាំយុ ត្រេដ** ១៦៦២

០៤-៣-២០០៥ -លិខិតលេខ ៥២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេឌូល** ១៦៦៤

០៤-៣-២០០៥ -លិខិតលេខ ៥២៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហាំយ៉ា (ខេមបូឌា) អ៊ិនធើណេសិនណល ត្រេដ** ១៦៦៦

០៤-៣-២០០៥ -លិខិតលេខ ៥២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ិនស្ត្រាក់ ខមភេនី** ១៦៦៨

០៤-៣-២០០៥ -លិខិតលេខ ៥៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គីម បូ ឌីវេឡុបមេន** ១៦៧០

០៤-៣-២០០៥ -លិខិតលេខ ៥៣៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហាប៊ីតា** ១៦៧២

០៩-៣-២០០៥ -លិខិតលេខ ៥៣៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អាយ.ស៊ី.ខេ គ្លូប៊ល** ១៦៧៤

០៩-៣-២០០៥ -លិខិតលេខ ៥៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហេង សេង លី ត្រេឌីង** ១៦៧៦

០៩-៣-២០០៥ -លិខិតលេខ ៥៣៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គ្រីសាដ (ខេមបូឌា) ខូ អិលធីឌី** ១៦៧៨

| | | |
|---|---|---|
| ០៩-៣-២០០៥ | -លិខិតលេខ ៥៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អេស.អេច.អិន ត្រេឌីង** | ១៦៨០ |
| ០៩-៣-២០០៥ | -លិខិតលេខ ៥៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **(ខេមបូឌា) អ៊ិនធើណេសិនណល ម៉ាញ អ៊ិនដាស្ទ្រី អ៊ិនវេសមេន អេន ឌីវេឡុបមេន** | ១៦៨២ |
| ០៩-៣-២០០៥ | -លិខិតលេខ ៥៤៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស ស៊ុថា អ៊ឹមផត អិចផត** | ១៦៨៤ |
| ០៩-៣-២០០៥ | -លិខិតលេខ ៥៤៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ជី.ធី.អិល អ៊ឹមផត អិចផត & ត្រេឌីង ខមភេនី** | ១៦៨៦ |
| ០៩-៣-២០០៥ | -លិខិតលេខ ៥៤៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ហាក់ ស្រ៊ុន លី អ៊ិនធើណេសិនណល ត្រេដ** | ១៦៨៨ |
| ០៩-៣-២០០៥ | -លិខិតលេខ ៥៤៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ធីន អ៊ិនជីនារីង** | ១៦៩០ |
| ០៩-៣-២០០៥ | -លិខិតលេខ ៥៤៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ធី.ខេ.ធីធី** | ១៦៩២ |
| ០៩-៣-២០០៥ | -លិខិតលេខ ៥៤៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អិន.អិន.ស៊ី** | ១៦៩៤ |


## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ១៤-៣-២០០៥ | -ប្រកាសលេខ ១៥៤ សហវ.ប្រក ស្តីពីការបំពេញបន្ថែមចំណាត់ថ្នាក់បំណុល សំរាប់ថវិកាសាលាខេត្ត ក្រុង | ១៦៩៦ |
| ១៤-៣-២០០៥ | -ប្រកាសលេខ ១៥៩ សហវ.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន | ១៦៩៨ |
| ១៥-៣-២០០៥ | -ប្រកាសលេខ ១៦១ សហវ.ពដ.ប្រក ស្តីពីកាតព្វកិច្ចសារពើពន្ធនៃកិច្ចលទ្ធកម្ម | ១៧០២ |
| ១៥-៣-២០០៥ | -ប្រកាសលេខ ១៦២ សហវ.ប្រក ស្តីពីការបង្កើតក្រុមការងារដើម្បីពិភាក្សាជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អំពីការប្រមូលពន្ធប្រថាប់ត្រា និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ | ១៧០៥ |

## ៣.ធនាគារជាតិ នៃកម្ពុជា


១០-៣-២០០៥ -ប្រកាសលេខ ធ៧.០៥.០៥៤ ប្រក ស្តីពីគោលនយោបាយឥណទាន នីតិវិធី និងសិទ្ធអំណាចផ្តល់ឥណទាន ១៧០៧

១០-៣-២០០៥ -PRAKAS Number B7.05.54 Prokor ON Loan Policies, Procedures and Lending Authority ១៧១១


## ៤.ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ


១៤-៣-២០០៥ -ប្រកាសលេខ ១៣២ ប្រក.កសក ស្តីពីអនុផលព្រៃឈើ ១៧១៥


## ៥.ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា


០១-៣-២០០៥ -សារាចរណែនាំលេខ ០១ អយក.សរណន ស្តីពីការប្រឡងបញ្ចប់ភូមិសិក្សាផ្នែកចំណេះទូទៅ បំពេញវិជ្ជាសាធារណៈ និងឯកជន ១៧៣៥

០១-៣-២០០៥ -សារាចរណែនាំលេខ ០២ អយក.សរណន ស្តីពីការរៀបចំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាចំណេះទូទៅ និងបំពេញវិជ្ជា ១៧៤០

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ:** ត្រូវបានកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា ដូចតទៅ :

**មាត្រា៤ថ្មី :** រាជបណ្ឌិតសភាកម្ពុជា មានសមាជិកបណ្ឌិតសភា បីប្រភេទ :

១- **សមាជិកពេញសិទ្ធិ** ត្រូវជ្រើសរើសតាមការបោះឆ្នោតសម្ងាត់ ក្នុងចំណោមសមាជិកបម្រុងនៃរាជបណ្ឌិតសភាកម្ពុជា ដែលកំពុងបំពេញភារកិច្ច ។ សមាជិកពេញសិទ្ធិអាចមានពី ៤០ ទៅ ៧០នាក់។

២. **សមាជិកបម្រុង** ត្រូវជ្រើសរើសតាមការបោះឆ្នោតសម្ងាត់ដោយសមាជិកពេញសិទ្ធិ ពីក្នុងចំណោមអ្នកមានសញ្ញាបត្របណ្ឌិត ដែលបានដាក់ពាក្យសុំចូល ។

៣. **សមាជិកសមាគមិក** និង**សមាជិកកិត្តិយស** ត្រូវជ្រើសរើសតាមការបោះឆ្នោតសម្ងាត់ដោយសមាជិកពេញសិទ្ធិ ពីក្នុងចំណោមជនជាតិខ្មែរ និងជនបរទេសដែលរស់នៅក្នុង ឬក្រៅប្រទេសកម្ពុជា ហើយដែលបានជួយឧបត្ថម្ភចំពោះការពង្រីកវប្បធម៌ និងវិទ្យាសាស្ត្រជាគុណប្រយោជន៍ ដល់ប្រទេសកម្ពុជា ។

**មាត្រា១០ថ្មី** : រាជបណ្ឌិតសភាកម្ពុជា ត្រូវគ្រប់គ្រងផ្ទាល់ដោយគណៈកម្មាធិការប្រតិបត្តិមួយ ដែលដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន និងអគ្គលេខាធិការជាជំនួយការ ។ ភារកិច្ចរបស់ប្រធាន អនុប្រធាន និងអគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស ។

**មាត្រា១១ថ្មី** : ប្រធាន អនុប្រធាន និងអគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា ត្រូវតែងតាំងដោយ ព្រះរាជក្រឹត្យ ។

**មាត្រា១២ថ្មី** : ប្រធាន អនុប្រធាន និងអគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា ត្រូវជ្រើសរើសដោយ សមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា តាមរយៈការបោះឆ្នោតសម្ងាត់ សម្រាប់អាណត្តិ៥ឆ្នាំ ។

**មាត្រា១៤ថ្មី** : ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានមួយរូបនៃរាជបណ្ឌិតសភាកម្ពុជា ត្រូវចាត់តាំងដោយប្រធានឱ្យដឹកនាំការងារជំនួស ។

**មាត្រា១៧ថ្មី** : មហាសន្និបាតវិសាមញ្ញ ត្រូវកោះប្រជុំ ៥ ឆ្នាំម្ដង ដើម្បីជ្រើសរើសប្រធាន អនុប្រធាន និងអគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិសម្រាប់អាណត្តិថ្មី ។ ក្នុងករណីដែលមហាសន្និបាតសាមញ្ញ និងវិសាមញ្ញជាន់ឆ្នាំគ្នា មហាសន្និបាតត្រូវប្រព្រឹត្តទៅតែមួយលើក ដោយបញ្ចូលរបៀបវារៈរួមគ្នា ។

**មាត្រា២០ថ្មី** : រាជបណ្ឌិតសភាកម្ពុជា មានវិទ្យាស្ថានឧបសម្ព័ន្ធ ដូចខាងក្រោមនេះ :

*១-វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ*

ក.ផ្នែកវប្បធម៌វិទ្យា

ខ.ផ្នែកសិល្បៈ និងឥស្សរិយយស

3/5

ន៩

គ.ផ្នែកស្ថាបត្យកម្ម

ឃ.ផ្នែកបុរាណវិទ្យា

ង.ផ្នែកសិល្បៈទស្សនីយភាព

*២-វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម*

ក.ផ្នែកធម្មសាស្ត្រ និងចរិយាសាស្ត្រ

ខ.ផ្នែកនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

គ.ផ្នែកពាណិជ្ជសាស្ត្រ និងការគ្រប់គ្រង

ឃ.ផ្នែកភូមិវិទ្យា និងនគរូបនីយកម្ម

ង. ផ្នែកប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រនយោបាយ

ច.ផ្នែកទស្សនវិជ្ជា និងសង្គមវិជ្ជា

ឆ.ផ្នែកនរវិទ្យា និងជាតិពន្ធុវិទ្យា

ជ.ផ្នែកវិទ្យាសាស្ត្រអប់រំ

*៣-វិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម*

ក.ផ្នែកបរិស្ថានធម្មជាតិ និងជីវវិទ្យា

ខ.ផ្នែកវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងឱសថសាស្ត្រ

គ.ផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឃ.ផ្នែកធនធានទឹក

*៤-វិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា*

ក.ផ្នែកគណិតវិទ្យា និងស្ថិតិ

ខ.ផ្នែកគីមី និងចំណីអាហារ

គ.ផ្នែករូបវិទ្យា និងថាមពល

ឃ.ផ្នែកបច្ចេកវិទ្យា

ង.ផ្នែកព័ត៌មានវិទ្យា និងទូរគមនាគមន៍

*៥-វិទ្យាស្ថានភាសាជាតិ*

ក.ផ្នែកខេមរនីយកម្ម វចនានុក្រម និងបកប្រែ

ខ.ផ្នែកភាសា និងភាសាវិទ្យា

គ.ផ្នែកអក្សរសាស្ត្រ និងអក្សរសិល្ប៍

ឃ.ផ្នែកសិលាចារឹកវិទ្យា

*៦-វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ*

ក.ផ្នែកទំនាក់ទំនងការទូត

ខ.ផ្នែកទំនាក់ទំនងវប្បធម៌ អប់រំ និងទេសចរណ៍

គ.ផ្នែកទំនាក់ទំនងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឃ.ផ្នែកទំនាក់ទំនងនយោបាយ និងសន្តិសុខ

ង.ផ្នែកទំនាក់ទំនងកសិកម្ម បរិស្ថាន និងថាមពល

ច.ផ្នែកទំនាក់ទំនងសង្គមកិច្ច និងសុខាភិបាល

រាជបណ្ឌិតសភាកម្ពុជា អាចបង្កើតវិទ្យាស្ថានឧបសម្ព័ន្ធផ្សេងទៀត ដោយអនុក្រឹត្យ តាមតម្រូវការចាំបាច់ ។

**មាត្រា៣** : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.០៥០៣.១១៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥

លេខ: ១០៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ៣ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុខ សាន់

5/5

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១១២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានទទួលការប្រោសប្រទាននូវគ្រឿង ឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ០៧ រូប ដូចមានរាយនាមខាងក្រោម :

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ជូនចំពោះ :

១- ឯកឧត្តម **ខៀវ សុភ័គ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ

២- លោក **សេ ធរុណ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូនចំពោះ :

១- លោក **សុខ សារីនុធ** នាយករងខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

២-លោក **យិន សុចិន្តចិន្តា** នាយករងខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

៣- លោក **ម៉ែន ប៊ុនរិទ្ធ** អនុប្រធានទី ១នាយកដ្ឋានកិច្ចការរដ្ឋបាលនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ

៤- លោក **ម៉ែន គុសល្យ** ជំនួយការឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

៥- លោក ឆា សុផល្លា ជំនួយការឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស-០៥០៣.១១៥

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ,ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥

លេខ : ១០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ មីនា. ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

នស/រកត/០៣០៥/១២០

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សត្តខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លីវនី ហ្គីល** ( LIVNI GIL ) ជនជាតិអ៊ីស្រាអែល សញ្ជាតិអាមេរិក កើតថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៦៨ នៅប្រទេសអ៊ីស្រាអែល ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*៣រល.០៥០៣.១២៣*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៥*

លេខ ១១០.ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៣ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សោម តាន់**

នស/រកត/០៣០៥/១២២

# ព្រះរាជក្រឹត្យ

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

**ក_ថ្នាក់ឧត្តមសេនីយ៍ឯក :**

១-លោកឧត្តមសេនីយ៍ត្រី ផន អ៊ឹម អត្តលេខ ០០៣២
២-លោកឧត្តមសេនីយ៍ត្រី ពត ត្រួច អត្តលេខ ០០៣៥
៣-លោកឧត្តមសេនីយ៍ត្រី ចោង លឹម អត្តលេខ ០០៤៨
៤-លោកឧត្តមសេនីយ៍ត្រី លន់ ឈោត អត្តលេខ ០០៥៤
៥-លោកឧត្តមសេនីយ៍ត្រី គួយ យ៉ារី អត្តលេខ ០០៥៧
៦-លោកឧត្តមសេនីយ៍ត្រី អុន ឈេន អត្តលេខ ០០៥៩

**ខ_ថ្នាក់ឧត្តមសេនីយ៍ត្រី :**

១-លោកវរសេនីយ៍ឯក អ៊ូ ហៃ អត្តលេខ ០១២១
២-លោកវរសេនីយ៍ឯក ទឹម ផន អត្តលេខ ០១៦៩
៣-លោកវរសេនីយ៍ឯក ប្រាក់ គុយឡេង អត្តលេខ ០២៣៤

៤-លោកវរសេនីយ៍ឯក ជា ចន្ថា អត្តលេខ ០២៦០

៥-លោកវរសេនីយ៍ឯក ជុំ ហាត អត្តលេខ ០៣៤១

៦-លោកវរសេនីយ៍ឯក រស់ នឹមសារុន អត្តលេខ ០៤០៥

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត/០៣០៥/១២៥

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០០៥*

លេខ ១១២ ច.ល

**ដើម្បីចម្លងចែកជូន**

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ០៣ ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**

ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **ឌុន លាន** ជា **អគ្គនាយក** នៃអគ្គនាយកដ្ឋានថាមពល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស-០៥០៣-១២៩

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ,ថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០០៥*

លេខ ១១១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ាន់ តាន់

2/2

នស/រកត/០៣០៥/១២៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** : តម្លើងឋានន្តរស័ក្តិ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាម ដូចខាងក្រោម ÷

**ក. តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ**

១-ឧត្តមសេនីយ៍ត្រី **ឃួន ខួន** អត្តលេខ ០០០២៤៦

២-ឧត្តមសេនីយ៍ត្រី **ឈឹម រចនា** អត្តលេខ ០០០២០៨

**ខ. តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី**

១-វរសេនីយ៍ឯក **គង់ សារី** អត្តលេខ ០០០៥៣៩

២-វរសេនីយ៍ឯក **គីម សំអូល** អត្តលេខ ០០៣៨៨២

៣-វរសេនីយ៍ឯក **នង ថាល់** អត្តលេខ ០០១៥៥៦

៤-វរសេនីយ៍ឯក ម៉ែត បុត្រ អត្តលេខ 000៥៩៨

៥-វរសេនីយ៍ឯក នួន សុខ អត្តលេខ 000៥៩៩

៦-វរសេនីយ៍ឯក ម៉ៅ ហាចណ្ណារស់ អត្តលេខ 000៩៧១

៧-វរសេនីយ៍ឯក ស៊ីសុចត្ថិ សុជាតិបុទ្ធុម អត្តលេខ 000៥៩៤

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.០៥០៣.១៣០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៥

លេខ ១០៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៣ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលខ្លឹមសារមាត្រា ៥ ជំពូកទី២ ផ្នែកទី១ នៃអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

-បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមលើអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ

-យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១.-**

ត្រូវបានកែសំរួលខ្លឹមសារក្នុងមាត្រា៥ ចំណុច៥.១ ជំពូកទី២ ផ្នែកទី១ នៃអនុក្រឹត្យលេខ១១៥ អនក្រ.បកចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល មានខ្លឹមសារដូចតទៅ :

**មាត្រា ៥ ថ្មី :**

៥.១-ក្រុមប្រឹក្សាភិបាលមានសមាជិក ១១ រូប ដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | - |
| - តំណាងក្រសួងបរិស្ថាន | - |
| - តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | - |
| - តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | - |
| - សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិកស្វ័យប្រវត្តិ |
| - តំណាងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| - តំណាងសភាពាណិជ្ជកម្ម | - |
| - តំណាងបុគ្គលិកសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិកស្វ័យប្រវត្តិ |

**មាត្រា២.-**

ក្រៅពីអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០០៤ និងក្រៅពីមាត្រា ៥ ថ្មីនេះ ខ្លឹមសារនៃអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ នៅរក្សាទុកជាធរមានដដែល ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ចាន់ សារុន**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ដូចមាត្រា៣
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧, ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាស់អោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១០០៤/ ០០៥ .ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក .ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក , ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២១៤ លានរៀល ( ពីររយ ដប់ប្រាំបួនលានរៀលគត់ ) ពីជំពូក ១០ ( បៀវត្ស និង ប្រាក់បំណាច់ ) ចំនួន ១៣៣ លានរៀល ( មួយរយ សាមសិបបីលានរៀលគត់ ) ពីជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) ចំនួន ៩ លានរៀល ( ប្រាំបួនលានរៀលគត់ ) និងពីជំពូក ៣២ ( អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ : វិភាគទានអោយអង្គការអន្តរជាតិនានា ) ចំនួន ៧៧ លានរៀល (ចិតសិបប្រាំពីរលានរៀលគត់ ) មកជំពូក១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈនិងការផ្គត់ផ្គង់ ) របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បំពេញមុខចំណាយដំណើរការរដ្ឋបាលឆ្នាំ ២០០៤ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

គង់ វិបុល

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប៉ូឡូញ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១:** ត្រូវបានបង្កើតស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប៉ូឡូញ ដោយមាននិវេសនដ្ឋាន នៅទីក្រុងវ៉ាស៊ូវី ។

**មាត្រា ២:** ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ។

**មាត្រា ៣:** សមាសភាពមន្ត្រីការទូតផ្សេងទៀត មន្ត្រីបច្ចេកទេស និងបុគ្គលិកសេវា នឹងត្រូវកំណត់តាមតំរូវការនៃការងារជាក់ស្តែង ។

**មាត្រា ៤:** ប្រព័ន្ធហិរញ្ញវត្ថុ សំរាប់មន្ត្រីការទូត មន្ត្រីបច្ចេកទេស និងបុគ្គលិកសេវា នៃស្ថានឯកអគ្គរាជទូតនេះនឹងស្ថិតនៅក្នុងប្រភេទ "ក" ។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...២៧៧អនក្រ.តត - ១៨

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ដើម្បីជួយកសាងសមិទ្ធផលនានា ជាច្រើន ដូចជា : កសាងសាលារៀន ០១ខ្នង មាន០៣បន្ទប់ ព្រះវិហារ កុដិ ឧបដ្ឋានសាលា នៅក្នុងវត្តព្រៃម្នាស់ ស្ថិតនៅឃុំសំឡី ស្រុកកំពង់រោទិ៍ និង វត្តថ្នឹង ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ឯកឧត្តម ឧត្តមសេនីយ៍ **ពៅ សារ៉ាន** មេបញ្ជាការរងយោធភូមិភាគ៥ ថវិកា ១៣.៥៤៨ ដុល្លារ

២-លោកជំទាវ **នឹម នេសាខ** ភរិយា ឯកឧត្តម ឧត្តមសេនីយ៍ **ពៅ សារ៉ាន** ថវិកា ១២.៨២៧ ដុល្លារ

៣-ឯកឧត្តម **គឹម នា** អភិបាលរងទី៣ ខេត្តស្វាយរៀង ថវិកា ១១.០០០ ដុល្លារ

៤-លោកស្រី **អ៊ុក ដារ៉ា** សប្បុរសជននៅខេត្តស្វាយរៀង ថវិកា ១៣.០៦៥ ដុល្លារ

៥-លោក **ទៀម និត** សប្បុរសជននៅខេត្តស្វាយរៀង ថវិកា ១២.១៣០ ដុល្លារ

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-ឯកឧត្តម **អ៊ិន សារឿន** សប្បុរសជននៅខេត្តស្វាយរៀង ថវិកា ១.២០០ ដុល្លារ

២-លោក **នុំ សារិទ្ធិ** សប្បុរសជននៅខេត្តស្វាយរៀង ថវិកា ១.៤៦៣ ដុល្លារ

៣-លោក **ទឹម រិទ្ធិ** សប្បុរសជននៅខេត្តស្វាយរៀង ថវិកា ១.១៨៨ ដុល្លារ

៤-លោក **សំ ចិន** សប្បុរសជននៅខេត្តស្វាយរៀង ថវិកា ១.០៥០ ដុល្លារ

៥-លោកស្រី **ហ៊ុំ គង់** សប្បុរសជននៅខេត្តស្វាយរៀង ថវិកា ១.១៦៣ ដុល្លារ

៦-លោក **ទោយ ជាខ** សប្បុរសជននៅខេត្តស្វាយរៀង ថវិកា ១.០០២ ដុល្លារ

៧-លោក **ខន វុន** សប្បុរសជននៅខេត្តស្វាយរៀង ថវិកា ១.០០២ ដុល្លារ

៨-លោកស្រី **ឃិន សាន** សប្បុរសជននៅខេត្តស្វាយរៀង ថវិកា ២.៤២២ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៣ ឆ្នាំ ២០០៥

ហ៊ុន សែន

**<u>កន្លែងទទួល</u> :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៣៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២ គ្រឿង ប្រគេន និង ជូនសប្បុរសជន ដែលបាន ខិតខំប្រឹងប្រែងចលនាពុទ្ធបរិស័ទ និង បរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ កុដិ សាលាបុណ្យ ក្លោងទ្វារ និង សាលាពុទ្ធិកបឋមសិក្សា នៅក្នុងវត្តជម្ពូសត្ថារាម (ហៅវត្តគ្រើល) ស្ថិតនៅក្នុងឃុំអណ្តូងពោធិ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដូចមានរាយព្រះនាម និង នាម ខាងក្រោម ÷

| | | |
|---|---|---|
| ១-ព្រះតេជគុណ | **សៀង ចាន់** | ព្រះចៅអធិការវត្ត ជម្ពូសត្ថារាម ចលនាពុទ្ធបរិស័ទ ជួយកសាង ព្រះវិហារ កុដិ សាលាបុណ្យ និង ក្លោងទ្វារ ។ |
| ២-លោកស្រី | **សៀង ឡូច** | សប្បុរសជនខ្មែររស់នៅប្រទេសអូស្ត្រាលី កសាងសាលាពុទ្ធិក-បឋមសិក្សា ០១ ខ្នង ថវិកា ១៥.០០០ ដុល្លារ |

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ធំ ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនលោក **ស៊ុយ អាន** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ដើម្បីជួយកសាងព្រះវិហារ និង សាលារៀនវត្តជ្រៃ ស្ថិតនៅក្នុងឃុំជ្រៃ ស្រុកព្រៃវែង ខេត្តព្រៃវែង ចំណាយថវិកាចំនួន ២៣.៧០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ.....២៣៨.០.....អនក្រ - ១៩

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ចំនួន ០២ គ្រឿង ជូនសប្បុរសជនជនជាតិកូរ៉េ ចំនួន ០២ រូប ដែលបានផ្តល់អំណោយជាម៉ាស៊ីនកុំព្យូទ័រចំនួន ២០២ គ្រឿង ម៉ាស៊ីនព្រីនធ័រចំនួន ២០ គ្រឿង និង សំលៀកបំពាក់ចំនួន ៤៣.០០០ កំប្លេ ជូនដល់សាលាខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម ÷

១-លោក **លី** **មូនស៊ុក** ( **Lee Moon Suk** ) នាយករងក្រុមហ៊ុន **SK**

២-លោក **លី** **ស៊ីយ៉ុង** ( **Lee Se Hyung** ) នាយករងក្រុមហ៊ុន **Good Morning Hill**

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ៣ ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៣៧.១....អនក្រ.បក-៩៩

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជនចំនួន ០៤ រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួម ជួយកសាងវិស័យព្រះពុទ្ធសាសនា នៅក្នុងវត្តត្រពាំងវែង ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម ÷

១-ឯកឧត្តម **ហ៊ីង ប៊ុនហៀង** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

២-លោកជំទាវ **វ៉ែន ចន្នី** ភរិយាឯកឧត្តម ហ៊ីង ប៊ុនហៀង

៣-លោក **អ៊ុយ សារិន** នាយកការិយាល័យត្រួតពិនិត្យទីចាត់ការគយ និង រដ្ឋាករ

៤-លោក **ឆិត ជា** នាយរងការិយាល័យត្រួតពិនិត្យទីចាត់ការគយនិង រដ្ឋាករ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ ៣ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤២.០៥.២៧...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការចំនួន ២០ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ÷

**ក-មេដាយមាសការងារ :**

| | | |
|---|---|---|
| ១-ឯកឧត្តម | **ជា សុខុម** | អគ្គលេខាធិការរងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ |
| ២-ឯកឧត្តម | **ម៉ៅ ញ៉ី** | ទីប្រឹក្សាសម្តេចអនុប្រធានទី១ រដ្ឋសភា |
| ៣-ឯកឧត្តម | **លី គឹមសុខ** | នាយកសាលាភូមិន្ទរដ្ឋបាល |
| ៤-លោកឧត្តមសេនីយ៍ត្រី | **មិន នឹម** | មេបញ្ជាការរងយោធភូមិភាគទី៣ |
| ៥-លោកវរសេនីយ៍ឯក | **ឈុំ អឿន** | ស្នងការនគរបាលខេត្តកំពង់ស្ពឺ |
| ៦-លោកវរសេនីយ៍ទោ | **មិន ស៊ីមិន** | មេបញ្ជាការរងកងរាជអាវុធហត្ថ ខេត្តកំពង់ស្ពឺ |
| ៧-លោកវរសេនីយ៍ទោ | **សោម សាម៉ុន** | មេបញ្ជាការរងកងរាជអាវុធហត្ថ ខេត្តកំពង់ស្ពឺ |
| ៨-លោកវរសេនីយ៍ទោ | **សម សាមួន** | ស្នងការរងនគរបាល ខេត្តកំពង់ស្ពឺ |
| ៩-លោក | **ជុំ ខន** | អភិបាលស្រុកគងពិសី ខេត្តកំពង់ស្ពឺ |
| ១០-លោកវរសេនីយ៍ត្រី | **ខេង សៅវិបុត្ត** | នាយរងការិយាល័យពិធីការ ទំនាក់ទំនងអន្តរជាតិនិងអាស៊ាន |

**គ-មេដាយគ្រឿងឥស្សរិយយសការងារ :**

១-លោកវរសេនីយ៍ឯក **ខួន ហុង** នាយទាហានកង ឯកភាពអង្គរក្ស

២-លោកវរសេនីយ៍ឯក **សុខ គឹមអេង** នាយទាហានកង ឯកភាពអង្គរក្ស

៣-លោកវរសេនីយ៍ឯក **ជី ពិសិដ្ឋ** នាយទាហានកង ឯកភាពអង្គរក្ស

៤-លោកវរសេនីយ៍ទោ **យី ឆៃយ៉ា** នាយទាហានកង ឯកភាពអង្គរក្ស

៥-លោកវរសេនីយ៍ទោ **សុខ សំអុល** នាយទាហានកង ឯកភាពអង្គរក្ស

៦-លោកវរសេនីយ៍ទោ **លឹម សុខា** នាយទាហានកង ឯកភាពអង្គរក្ស

៧-លោកវរសេនីយ៍ទោ **សំ សំអុល** នាយទាហានកង ឯកភាពអង្គរក្ស

៨-លោកវរសេនីយ៍ទោ **ទឹម សំអូន** នាយទាហានកង ឯកភាពអង្គរក្ស

៩-លោកវរសេនីយ៍ទោ **ទៅ សំ** នាយទាហានកង ឯកភាពអង្គរក្ស

១០-លោកវរសេនីយ៍ទោ **ឈាង សារុន** នាយទាហានកង ឯកភាពអង្គរក្ស

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...២៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ២៥ រូប ដែលបានចំណាយធនធានផ្ទាល់ខ្លួន ក្នុងការចូលរួមជួយកសាងវិស័យព្រះពុទ្ធសាសនា នៅក្នុងវត្តត្រពាំងវែង ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម ÷

១-ព្រះតេជគុណ **ពៅ ពិសី** ព្រះចៅអធិការវត្តត្រពាំងវែង

២-លោកយាយឧបាសិកា **នាត់ ឡឹម** សប្បុរសជន

៣-លោកយាយឧបាសិកា **សុខ ជុំ** សប្បុរសជន

៤-ឯកឧត្តម **ចាប ញ៉ាំលីមុច** អភិបាលខេត្ត កំពង់ស្ពឺ

៥-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ចៅ តុល** ជំនួយការផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី

៦-ឯកឧត្តម ឧត្តមសេនីយ៍ទោ **សួស អង្គារ** ប្រធាននាយកដ្ឋានស្ថិតិ និងលិខិតឆ្លងដែន

៧-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ឃុន ខុន** អគ្គនាយករងអគ្គនាយកដ្ឋានប្រេងឥន្ធនៈ ក្រសួងការពារជាតិ

៨-ឯកឧត្តម **មួន លីមឆេង** ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី

៩-ឯកឧត្តម **គង់ ចាំង** អភិបាលរង ខេត្តកំពង់ស្ពឺ

| | | |
|---|---|---|
| ១០-លោកឧត្តមសេនីយ៍ត្រី | ហ៊ឿង ឫទ្ធី | នាយរងសេនាធិការ កងឯកភាពអង្គរក្ស សម្តេចនាយករដ្ឋមន្ត្រី |
| ១១-លោក | ឃាង ធិសួរ | អគ្គនាយកក្រុមហ៊ុន សួរ កំណើន |
| ១២-លោក | ឃាង ឆាក់សួរ | អគ្គនាយករងក្រុមហ៊ុន សួរ កំណើន |
| ១៣-លោក | ម៉ែន សំបូរ | នាយខុទ្ទកាល័យសាលា ខេត្តកំពង់ស្ពឺ |
| ១៤-ឧកញ៉ា | ខេន សុភា | នាយកក្រុមហ៊ុន ខេន សុភា |
| ១៥- លោកវរសេនីយ៍ឯក | ហួត គឹមសាន | ជំនួយការឯកឧត្តម ហ៊ីង ប៊ុនហៀង |
| ១៦-លោកវរសេនីយ៍ទោ | ស៊ុន ហួរ | ជំនួយការឯកឧត្តម ហ៊ីង ប៊ុនហៀង |
| ១៧-លោកវរសេនីយ៍ទោ | លឹម រចនា | ជំនួយការឯកឧត្តម ហ៊ីង ប៊ុនហៀង |
| ១៨-លោក | គង់ សាង | នាយកក្រុមហ៊ុន ជូ អ៊ីមអាយ |
| ១៩-លោក | លាង ឃុន | នាយកក្រុមហ៊ុន ជីបម៉ុង |
| ២០-លោក | លាង ម៉េង | នាយកក្រុមហ៊ុន ប៉េង ហួត |
| ២១-លោកស្រី | ម៉ែន មាលីរតន៍ | សប្បុរសជន |
| ២២-លោកស្រី | គុម ធុំ | សប្បុរសជន |
| ២៣-លោក | ឡាំ ហេងហួត | មន្ត្រីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ២៤-លោក | សង់ សិទ្ធានិត្យ | មន្ត្រីទីចាត់ការគយ និងរដ្ឋាករ |
| ២៥-លោក | អៀង សុខ | ប្រធានស្ថានីយ៍ប្រេងឥន្ធនៈសូគីម៉ិចផ្សារថ្មី១ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០០៥

**សម្តេចនាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគថវិកាចូលរួមជួយកសាងសមិទ្ធផលជាប្រយោជន៍សាធារណៈ នៅក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក **តែ ចាំង** មន្ត្រីអង្គភាពទីចាត់ការទំនាក់ទំនងអគ្គមេបញ្ជាការប្រចាំព្រំដែនកម្ពុជា-ថៃ បានជួយកសាងផ្លូវចំនួន០២ខ្សែ មួយខ្សែប្រវែង ២៦គីឡូម៉ែត្រ និងមួយខ្សែទៀត ប្រវែង ១.៦០០ម៉ែត្រ នៅក្នុងឃុំស្លក្រាម ឃុំតាបែន និង ឃុំស្វាយចេក ចំណាយអស់ទឹកប្រាក់ ចំនួន ២៣១.៤០០ ដុល្លារ ។

២-លោកស្រី **ចក់ ពួក** សមាជិកាគណៈកម្មាធិការសាខាកាកបាទក្រហម ខេត្តបន្ទាយមានជ័យ ជួយកសាងផ្លូវលំ ក្រាលគ្រួសក្រហម មួយខ្សែប្រវែង ៨០០ម៉ែត្រ និងស្រះទឹក០២កន្លែង នៅក្នុងឃុំតាបែន ចំណាយអស់ទឹកប្រាក់ ចំនួន ២១.០០០ ដុល្លារ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ៣ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..២៣៥....អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤៥ ពណ.នគក

ភ្នំពេញថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០០៥

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ភី. ខេ. ភីភី**

**P. K. PP Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7520/05P ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ទិច សុខាថា** ប្រធានក្រុមប្រឹក្សាភិបាល

លោក BUCHY PHILIPPE អភិបាល

លោកស្រី **អ៊ុំ ស៊ីផុន** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ៤២ S ផ្លូវទន្លេមេគង្គ សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង [illegible]

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

លេខ ៥៥៦ ពណ.នគក

ភ្នំពេញថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៥

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អិន. អិន. ស៊ី**

N . N . C Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2290/05E ចុះថ្ងៃទី ០៧ ខែ មិនា ឆ្នាំ ២០០៥

មានទម្រង់ជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក CHO KU HO

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៩៣ ផ្លូវមុនីរ៉េត សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកក់រៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេ[illegible] និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត (Resort)

-វិនិយោគលើវិស័យកសិកម្ម : ដាំដុះ ចិញ្ចឹមសត្វ ។

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

[illegible]

គឹម_ស៊ីថន

**<u>ចំលងជូន</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៥៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពីការបំពេញបន្ថែមចំណាត់ថ្នាក់ចំណូល សំរាប់ថវិកាសាលាខេត្ត ក្រុង

********

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រម ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- បានឃើញព្រះរាជក្រម នស/រកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត-ក្រុង
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១** : អនុលោមតាមខ្លឹមសារ មាត្រា ៨ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ត្រូវបានបង្កើតបន្ថែមនៅក្នុងចំណាត់ថ្នាក់ចំណូលថវិកា សាលាខេត្ត ក្រុង ដូចខាងក្រោម ÷

ប្រភេទទី ១ : ពន្ធ និង អាករ

. ជំពូក ១២ : ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិ និង សេវា

. ប្រការ ០៩ : អាករលើការស្នាក់នៅ

**ប្រការ ២** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ ឯកឧត្តមអភិបាលគ្រប់ខេត្ត ក្រុង លោកប្រធាននាយកដ្ឋានពន្ធដារ លោកប្រធាននាយកដ្ឋានថវិកា លោកប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធជាអ្នកទទួលអនុវត្តប្រកាសនេះ ។

**ប្រការ ៣** : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

ចំលងជូន

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

  " ដើម្បីជូនជ្រាប "
- ដូចប្រការ ២

  " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ:..........សហវ.ប្រក

ភ្នំពេញ,ថ្ងៃទី........ខែ........ឆ្នាំ ២០០៥

# ប្រកាស
## ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ
## នៃនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន

~~~~~~~~~~

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្ដីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញតំរូវការចាំបាច់នៃការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
~~~~~~~~~~

## សំរេច

**ប្រការ១** : នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន គឺជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការអនុវត្តគោលនយោបាយហិរញ្ញវត្ថុវិសហមជ្ឈការ និងវិមជ្ឈការ របស់រាជរដ្ឋាភិបាល ដែលមានតួនាទីនិងភារកិច្ចសំខាន់ៗដូចខាងក្រោម ÷

- ចាត់តាំងអនុវត្តគោលនយោបាយហិរញ្ញវត្ថុវិសហមជ្ឈការ និង វិមជ្ឈការ
- សិក្សាស្រាវជ្រាវ និងផ្តល់យោបល់ ក្នុងការកសាងគោលនយោបាយ ហិរញ្ញវត្ថុវិសហមជ្ឈការ និងវិមជ្ឈការរបស់រាជរដ្ឋាភិបាល
- ចាត់តាំងអនុវត្តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- ចាត់តាំងអនុវត្តជំពូកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- រៀបចំរាល់លិខិតបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានាសំរាប់បំរើអោយការគ្រប់គ្រងហិរញ្ញវត្ថុថវិកានៅខេត្ត ក្រុង និង ឃុំ សង្កាត់
- សហការជាមួយ ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីជួយដល់ខេត្ត ក្រុង និង ឃុំ សង្កាត់ ក្នុងការរៀបចំនិងអនុវត្តថវិកា
- ជាសមភាគីការងារវិសហមជ្ឈការ និង វិមជ្ឈការជាមួយ ស្ថាប័ន អង្គភាព ឬ ចូលរួមវេទិកានានា ស្តីពីកំណែទំរង់វិសហមជ្ឈការ និងវិមជ្ឈការ ។
- ជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់ និងជាដៃគូ នៃគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលាប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ២** : នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ៣** : នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន មានការិយាល័យចំណុះចំនួនបី គឺ :

១-ការិយាល័យគ្រប់គ្រងហិរញ្ញវត្ថុ សាលាខេត្ត ក្រុង

២-ការិយាល័យគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់

៣-ការិយាល័យរដ្ឋបាល

**ប្រការ៤** : តួនាទីនិងភារកិច្ចរបស់ការិយាល័យគ្រប់គ្រង ហិរញ្ញវត្ថុ សាលាខេត្ត ក្រុង

- ចាត់តាំងអនុវត្តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- សហការជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រតនាគារខេត្ត ក្រុង ណែនាំអំពីបច្ចេកទេសក្នុងការរៀបចំនិងអនុវត្តថវិការបស់ខេត្ត ក្រុង
- រៀបចំតួលេខ ត្រួតពិនិត្យចំណូល ចំណាយថវិការបស់ខេត្ត ក្រុង
- រៀបចំកម្មវិធីចំណូល ចំណាយថវិកាប្រចាំត្រីមាសរបស់ខេត្ត ក្រុង

- សហការជាមួយអង្គភាពចំណុះក្រសួងមហាផ្ទៃ និងអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលពាក់ព័ន្ធ ក្នុងការរៀបចំគំរោងថវិកា និងប្រកាសថវិកាប្រចាំឆ្នាំជូនដល់ខេត្ត ក្រុងនីមួយៗ
- រៀបចំប្រកាសណែនាំអនុវត្តថវិកាខេត្ត ក្រុង ប្រចាំឆ្នាំនីមួយៗ
- ស្រាវជ្រាវ កសាងសេចក្តីព្រាង លិខិតបទដ្ឋាននានា ដែលបំរើអោយការគ្រប់គ្រងហិរញ្ញវត្ថុថវិកា របស់ខេត្ត ក្រុង
- ពិនិត្យ ផ្តល់យោបល់ និងរៀបចំអាណត្តិ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការផ្តល់ឧបត្ថម្ភ តុល្យភាព ថវិកាជូនខេត្ត ក្រុង
- ពិនិត្យ និងផ្តល់យោបល់ លើសំណើបន្ថែម ឬចលនាឥណទាន ថវិការបស់សាលាខេត្ត ក្រុង
- រៀបចំប្រកាសណែនាំបិទបញ្ជីចំណូល ចំណាយ និងសំរេចទូទាត់ថវិកាខេត្ត ក្រុង ប្រចាំឆ្នាំនីមួយៗ
- បូកសរុប និងត្រួតពិនិត្យរបាយការណ៍ចំណូល ចំណាយប្រចាំខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំ
- បូកសរុប និង រៀបចំរបាយការណ៍សំរេចទូទាត់ថវិកាខេត្ត ក្រុង ។

**ប្រការ៥** : តួនាទី និងភារកិច្ចរបស់ការិយាល័យគ្រប់គ្រង ហិរញ្ញវត្ថុ ឃុំ សង្កាត់

- អនុវត្តគោលនយោបាយ ហិរញ្ញវត្ថុវិមជ្ឈការ របស់រាជរដ្ឋាភិបាល
- ជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់
- សំរបសំរួល និងធ្វើកំណត់ហេតុរាល់ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់
- ចាត់តាំងអនុវត្តជំពូកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់
- សហការជាមួយអង្គភាពចំណុះក្រសួងមហាផ្ទៃ និងអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលពាក់ព័ន្ធក្នុងការរៀបចំលិខិតបទដ្ឋាននានា សំរាប់បំរើដល់ការគ្រប់គ្រងហិរញ្ញវត្ថុថវិកាឃុំ សង្កាត់
- សហការជាមួយសាលាខេត្ត ក្រុង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារខេត្ត ក្រុងណែនាំអំពី បច្ចេកទេសក្នុងការរៀបចំ និងអនុវត្តថវិការបស់ឃុំ សង្កាត់
- រៀបចំអាណត្តិជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបញ្ជូនថវិការដ្ឋទៅចូលរួមក្នុងមូលនិធិឃុំ សង្កាត់ សំរាប់ឆ្នាំនីមួយៗ
- សិក្សាស្រាវជ្រាវ និងផ្តល់យោបល់អំពីកំរិតនៃចំណែកចំណូលចរន្តរបស់ថវិការដ្ឋ ដែលត្រូវចូល រួមក្នុងមូលនិធិ ឃុំ សង្កាត់
- ផ្តល់យោបល់ ក្នុងការរៀបចំរូបមន្តបែងចែកធនធាននៃមូលនិធិឃុំ សង្កាត់
- ផ្តល់យោបល់ ក្នុងការរៀបចំចំណាត់ថ្នាក់ ដើម្បីបែងចែកប្រភេទឃុំ សង្កាត់ សំរាប់ឆ្នាំនីមួយៗ
- រៀបចំប្រកាសជូនដំណឹងដល់ឃុំ សង្កាត់នូវធនធាន ដែលត្រូវទទួលបានសំរាប់ឆ្នាំនីមួយៗ
- តាមដានការផ្ទេរជាក់ស្តែងនូវធនធានមូលនិធិឃុំ សង្កាត់ ពីគណនីរតនាគារជាតិទៅគណនីឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុង

- រៀបចំរបាយការណ៍បូកសរុបហិរញ្ញវត្ថុថវិកាឃុំ សង្កាត់ និងរបាយការណ៍ហិរញ្ញវត្ថុ របស់មូលនិធិឃុំ សង្កាត់ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ។

**ប្រការ៦** : តួនាទី និង ភារកិច្ចរបស់ការិយាល័យរដ្ឋបាលៈ

- ចាត់តាំងអនុវត្តការងាររដ្ឋបាល ផ្ទៃក្នុងរបស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន
- សហការជាមួយគ្រប់ការិយាល័យចំណុះនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ដើម្បីរៀបចំការងារបូកសរុបកសាងរបាយការណ៍ហិរញ្ញវត្ថុថវិការបស់សាលាខេត្ត ក្រុង និងរបាយការណ៍ហិរញ្ញវត្ថុថវិការបស់ឃុំ សង្កាត់
- ផ្សព្វផ្សាយសេចក្តីជូនដំណឹង និងលិខិតបទដ្ឋានផ្សេងៗ
- តំកល់ និងថែរក្សាឯកសារផ្សេងៗ របស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន
- គ្រប់គ្រងកុំព្យូទ័រ និងសំភារៈការិយាល័យរបស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន
- គ្រប់គ្រងបញ្ជីបុគ្គលិក រៀបចំការងារបណ្តុះបណ្តាល និង របបឧបត្ថម្ភផ្សេងៗដល់មន្ត្រីរាជការក្នុង នាយកដ្ឋាន ហិរញ្ញវត្ថុមូលដ្ឋាន ។

**ប្រការ៧** : ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធ នឹងសមត្ថកិច្ចរបស់នាយកដ្ឋាន ឬ អង្គភាពជំនាញដទៃ ប្រធាននាយកដ្ឋាន ត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធនោះ សុំគោលការណ៍ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរួមគ្នាដោះស្រាយ ។

**ប្រការ៨** : ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយនាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៩** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានថវិកា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន និងគ្រប់នាយកដ្ឋានដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល "ដើម្បីជូនជ្រាបជាពត៌មាន"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០១ សហវ.ពន.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៥

# ប្រកាស
## ស្តីពី
## ភារកិច្ចកិច្ចសារពើពន្ធនៃកិច្ចលទ្ធកម្ម

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៧/នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ និងព្រះរាជក្រមលេខ ០៨/នស/៩៤ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ និងព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញប្រកាសលេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ
- បានឃើញប្រកាសលេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់បៀវត្ស
- បានឃើញប្រកាសលេខ០៨៣ សហវ.ប្រក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៣ ស្តីពីការណែនាំអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសារាចរណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៣ ស្តីពីការអនុវត្តន៍កិច្ចលទ្ធកម្មសាធារណៈសំរាប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ អង្គភាពស្វយ័តគ្រប់គ្រង
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់នាយកដ្ឋានពន្ធដារ ។

## សំរេច:

**ប្រការ ១.-**

អ្នកជាប់ពន្ធដែលបានចុះកិច្ចសន្យាលទ្ធកម្មសាធារណៈទូទៅ ឬកិច្ចសន្យាលទ្ធកម្មនៃគំរោងថវិកាវិនិយោគឃុំ-សង្កាត់ ដោយអនុវត្តនូវវិធីសាស្ត្រទិញផ្ទាល់ ចុះកិច្ចសន្យាផ្ទាល់ ស្ទង់តំលៃក្នុងស្រុក ដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក ដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើការផ្គត់ផ្គង់ទំនិញ សេវា ជួសជុល និងការសាងសង់គ្រប់ប្រភេទឱ្យដល់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ អង្គភាពស្វ័យគ្រប់គ្រងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ឬសំរាប់អភិវឌ្ឍន៍ឃុំ-សង្កាត់ ត្រូវបំពេញនូវកាតព្វកិច្ចសារពើពន្ធដូចតទៅ :

ក- ចំពោះអ្នកជាប់ពន្ធតាមរបបពិតត្រូវ :

- បង់ពន្ធលើប្រាក់ចំណេញទៅតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់ចំណេញ
- បង់អាករលើតំលៃបន្ថែមតាមអត្រា ១០% ដោយយកតំលៃកិច្ចសន្យាចែកនឹង ១១
- បង់ពន្ធលើប្រាក់បៀវត្សតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់បៀវត្ស
- បង់ពន្ធប៉ាតង់ និង
- ពន្ធ-អាករដទៃទៀត តាមការតំរូវនៃច្បាប់ស្តីពីសារពើពន្ធ ។

ខ- ចំពោះអ្នកជាប់ពន្ធតាមរបបម៉ៅការត្រូវ :

- បង់ពន្ធលើប្រាក់ចំណេញម៉ៅការទៅតាមអត្រា ១% នៃតំលៃកិច្ចសន្យា ។
- បង់អាករលើផលរបរទៅតាមអត្រា ២% នៃតំលៃកិច្ចសន្យា ។

ប្រាក់ពន្ធលើប្រាក់ចំណេញម៉ៅការ និងប្រាក់អាករលើផលរបរដែលត្រូវបង់ គឺយកតំលៃកិច្ចសន្យា គុណនឹង ៣ ហើយចែកនឹង ១០០ ។

- បង់ពន្ធលើប្រាក់បៀវត្សទៅតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់បៀវត្ស
- បង់ពន្ធប៉ាតង់ និង
- ពន្ធ-អាករដទៃទៀត តាមការតំរូវនៃច្បាប់ស្តីពីសារពើពន្ធ ។

**ប្រការ ២.-**

១- អ្នកជាប់ពន្ធតាមរបបពិតដែលបានចុះកិច្ចសន្យាលទ្ធកម្មសាធារណៈទូទៅ និង កិច្ចសន្យាលទ្ធកម្មនៃគំរោងថវិកាវិនិយោគឃុំ-សង្កាត់ ត្រូវធ្វើការបង់ប្រាក់អាករលើតំលៃបន្ថែម តាមរូបមន្តដូចមានចែងក្នុងប្រការ ១ កថាខ័ណ្ឌ ក ខាងលើ តាមវិធីកាត់ទុកជាមុនពីអាណត្តិកិច្ចទូទាត់ដោយរតនាគារជាតិ អង្គភាពគ្រប់គ្រង រូបិយប័ណ្ណ ឬរតនាគារខេត្ត-ក្រុង ។

២- អ្នកជាប់ពន្ធតាមរបបម៉ៅការដែលបានចុះកិច្ចសន្យាលទ្ធកម្មសាធារណៈទូទៅ និង កិច្ចសន្យាលទ្ធកម្មនៃគំរោងថវិកាវិនិយោគឃុំ-សង្កាត់ ត្រូវធ្វើការបង់ប្រាក់អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញម៉ៅការ តាមរូបមន្តដូចមានចែងក្នុងប្រការ ១ កថាខ័ណ្ឌ ខ ខាងលើ ដោយវិធីកាត់ទុកជាមុនពីអាណត្តិកិច្ចទូទាត់ដោយរតនាគារជាតិ អង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ឬរតនាគារខេត្ត-ក្រុង ។

៣- ក្រៅពីអាករលើតំលៃបន្ថែម (សំរាប់អ្នកជាប់ពន្ធតាមរបបពិត) អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញម៉ៅការ (សំរាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ) ដែលត្រូវបង់តាមវិធីកាត់ទុកពីអាណត្តិកិច្ចទូទាត់ដោយរតនាគារជាតិ អង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ឬរតនាគារ ខេត្ត-ក្រុង អ្នកជាប់ពន្ធត្រូវធ្វើការប្រកាស និងបង់ពន្ធអាករដទៃទៀតនៅអង្គភាពពន្ធដារ ។

៤- ការកាត់ទុកប្រាក់ពន្ធអាករពីអាណត្តិកិច្ចទូទាត់ដោយរតនាគារជាតិ អង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ឬរតនាគារខេត្ត-ក្រុង ពុំធ្វើឱ្យអ្នកជាប់ពន្ធរួចផុតពីកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ។ រៀងរាល់ខែ អ្នកជាប់ពន្ធតាមរបបពិតដែលបានចុះកិច្ចសន្យាលទ្ធកម្មសាធារណៈទូទៅ និង កិច្ចសន្យាលទ្ធកម្មនៃគំរោងថវិកាវិនិយោគឃុំ-សង្កាត់ ត្រូវដាក់លិខិតប្រកាសអាករលើតំលៃបន្ថែមដោយបញ្ជាក់អំពីអាករលើធាតុចូល អាករលើធាតុចេញ និង ទឹកប្រាក់ត្រូវបង់ទៅតាមសភាពជាក់ស្តែង ។ ប្រសិនបើទឹកប្រាក់អាករដែលបានកាត់ទុកពីអាណត្តិកិច្ចទូទាត់មានចំនួនលើសពីចំនួនទឹកប្រាក់អាករត្រូវបង់ ចំនួនលើសត្រូវបានអនុញ្ញាតជាឥណទានសំរាប់យោងទៅមុខ ឬបង្វិលសង ។

**ប្រការ ៣.-**

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ប្រធានអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត-ក្រុង ប្រធានរតនាគារខេត្ត-ក្រុង ប្រធានសាខាពន្ធដារខេត្ត-ក្រុង និងប្រធានអង្គភាពលទ្ធកម្មនៃក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជាឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង
- អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៦២ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារ ដើម្បីពិភាក្សាជាមួយ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អំពីការប្រមូលពន្ធប្រថាប់ត្រា និងពន្ធលើដីធ្លីមិនបានប្រើប្រាស់

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច :

**ប្រការ១ :** បង្កើតក្រុមការងារ ដើម្បីពិភាក្សាជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អំពីការប្រមូលពន្ធប្រថាប់ត្រា និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដែលរួមមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ហង់ ជួនណារ៉ុន | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២- | លោក កាំង ឈាងខ័ណ្ឌ | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | អនុប្រធាន |
| ៣- | លោក ឈីវ ប៊ុនហៃ | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន | សមាជិក |
| ៤- | លោក ឈិម អឿង | ប្រធាននាយកដ្ឋានពន្ធដារ | សមាជិក |
| ៥- | លោក ប៉ែន វុត្ថា | អនុប្រធានទី១ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៦- | លោក ទាត់ ស៊ុំ | អនុប្រធាននាយកដ្ឋានពន្ធដារ | សមាជិក |
| ៧- | លោក កែវ វាធ់ | ប្រធានសាខាពន្ធដាររាជធានីភ្នំពេញ | សមាជិក |
| ៨- | លោក ទី សុផាត | ប្រធានសាខាពន្ធដារខេត្តសៀមរាប | សមាជិក |
| ៩- | លោក ទាវ សាវឿន | ប្រធានសាខាពន្ធដារខេត្តកណ្តាល | សមាជិក |
| ១០- | លោក អោម ចន | ប្រធានសាខាពន្ធដារខេត្តស្វាយរៀង | សមាជិក |
| ១១- | លោក ថា ចិសិដ្ឋ | ប្រធានសាខាពន្ធដារខេត្តកំពត | សមាជិក |

**ប្រការ២ :** ក្រុមការងារនេះ មានភារកិច្ចរៀបចំឯកសារមួយចំនួនទាក់ទងនឹងការប្រមូលពន្ធប្រថាប់ត្រា លើការផ្ទេរអចលនវត្ថុ សំរាប់ការប្រជុំពិភាក្សាជាមួយមន្ត្រីជំនាញនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដូចតទៅ :

- វិធានការដើម្បីកំណត់តំលៃនៃការទិញ-លក់អចលនវត្ថុ ដែលជាមូលដ្ឋាននៃការគិតពន្ធឱ្យបានខិតជិតទៅនឹងតំលៃពិតរបស់អចលនវត្ថុ
- នីតិវិធីនៃការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធ ចំពោះអចលនវត្ថុមិនទាន់ចុះបញ្ជី
- លទ្ធភាពបញ្ចុះអត្រាពន្ធប្រថាប់ត្រា
- យន្តការនៃការប្រមូលពន្ធប្រថាប់ត្រា និងពន្ធលើដីធ្លីមិនបានប្រើប្រាស់
- អំពីខ្ទង់ចំណូលពីពន្ធប្រថាប់ត្រាក្នុងថវិកាជាតិ
- កំរិតនៃការលើកទឹកចិត្តសំរាប់ផ្តល់ជូនរដ្ឋបាលសុរិយោដីផ្នែកពន្ធដារ និងរដ្ឋអំណាចឃុំ-សង្កាត់ ក្នុងការប្រមូលពន្ធប្រថាប់ត្រា

**ប្រការ៣ :** ក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងត្រូវធ្វើរបាយការណ៍ជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាប្រចាំអំពីលទ្ធផលដែលខ្លួនសំរេចបានក្នុងការបំពេញភារកិច្ចខាងលើ ហើយជាយថាហេតុសុំការណែនាំ និងវិធានការសំរាប់កិច្ចការនេះឱ្យមានប្រសិទ្ធិភាព ។

**ប្រការ៤ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង និង ឯកឧត្តម អស់លោក ដែលមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៥

គាត ឈន់

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ "ដើម្បីជូនជ្រាប"
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០៥.០៥៤ ប្រ.ក

# ប្រកាស

## ស្តីពី

## គោលនយោបាយឥណទាន នីតិវិធី និងសិទ្ធអំណាចផ្តល់ឥណទាន

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាថ្ងៃទី ០៤ ខែមិនា ឆ្នាំ ២០០៥

## ស ំ រេ ច

**ប្រការ ១.-**

រាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តអោយបានស្របតាមគោលនយោបាយឥណទានត្រឹមត្រូវនិងប្រុងប្រយ័ត្ន ការប្រតិបត្តិជាទូទៅនិងនីតិវិធីក្នុងការផ្តល់ឥណទានដែលត្រូវតែបានអនុម័តនិងពិនិត្យឡើងវិញដោយត្រឹមត្រូវពីគណៈគ្រប់គ្រង និង/ឬក្រុមប្រឹក្សាភិបាល ។

**ប្រការ ២.-**

រាល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវបង្កើត :

១- គោលនយោបាយនិងនីតិវិធីជាលាយល័ក្សអក្សរសំរាប់ដាក់ចេញនូវគោលនយោបាយឥណទាន នីតិវិធីនិងកំណត់សិទ្ធអំណាចអោយខ្ញីរបស់មន្ត្រីឥណទាន និង/ឬគណៈ

កម្មការឥណទាន និងក្រុមប្រឹក្សាភិបាល ហើយគោលនយោបាយនិងនីតិវិធីទាំងនោះ ត្រូវតែបានបញ្ជូនទៅគ្រប់បុគ្គលិក ដែលពាក់ព័ន្ធនឹងសកម្មភាពផ្តល់ឥណទាន ។

២- សំណុំឯកសារឥណទានរបស់អ្នកសុំខ្ចីទាំងអស់ត្រូវតែមានព័ត៌មានថ្មីៗគ្រប់គ្រាន់ និងអាចជឿទុកចិត្តបាន ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ ។

**ប្រការ ៣.-**

គោលនយោបាយឥណទាន នីតិវិធីនិងសិទ្ធអំណាចអោយខ្ចីត្រូវមាន ការវិភាគឥណទាន ដំណើរការអនុម័តឥណទាន នីតិវិធីពិនិត្យឥណទានឡើងវិញតាមគ្រា កំរិតកំណត់អនុម័តឥណទានរបស់មន្ត្រី និង/ឬ គណៈកម្មការឥណទាន វត្ថុធានា និងពត៌មានចាំបាច់ផ្សេងៗទៀត ។

**ប្រការ ៤.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០០៥

**ទេសាភិបាល**

**ជា-ចាន់តូ**

**__កន្លែងទទួល__**

- ដូចប្រការ៤" ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**__ចម្លងជូន__**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"

**ឧបសម្ព័ន្ធ:**

ប្រកាសលេខ ធ៧.០៥-០៥៤ប្រក
ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ២០០៥

## ព័ត៌មានដែលត្រូវរក្សាទុកក្នុងសំណុំឯកសារឥណទាន

### I ព័ត៌មានអំពីអ្នកសុំខ្ចី

ក- រូបវន្តបុគ្គល ÷ អាស័យដ្ឋាន អាស័យដ្ឋានទំនាក់ទំនង មុខរបរ និយោជក ប្រវត្តិ និងឬ ចំណូល ស្ថានភាពហិរញ្ញវត្ថុ និងឬ មូលនិធិផ្ទាល់សុទ្ធ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

ខ- និតិបុគ្គល ÷ លក្ខន្តិកៈក្រុមហ៊ុន ឯកកម្មសិទ្ធិ ឬ សហកម្មសិទ្ធិ ប្រវត្តិ និងសាវតាអាជីវកម្ម រចនាសម្ព័ន្ធចាត់តាំងក្រុមហ៊ុន គណៈគ្រប់គ្រង នាយក ភាគទុនិក ម្ចាស់កម្មសិទ្ធិ សហកម្មសិទ្ធិ ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផល និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

### II ព័ត៌មានអំពីការផ្ដល់ឥណទាន

ក- ពិពណ៌នាពីប្រភេទឥណទាន (ឥណទានវិបារូបន៍ ឥណទានបង្វិលជុំ ឥណទានសងរំលោះ ចំនួនប្រាក់ ប្រភេទរូបិយប័ណ្ណ)

ខ- គោលបំណងឥណទាន

គ- លក្ខខ័ណ្ឌឥណទាន ÷ ការិតកំណត់ អត្រាការប្រាក់ តារាងពេលវេលាសងប្រាក់ រយៈពេល កាលកំណត់ និងកាលបរិច្ឆេទផុតកំណត់

ឃ- វត្ថុធានា ÷ លេខប័ណ្ណកម្មសិទ្ធិវត្ថុធានា ទីតាំង ប្រភេទ ចំនួនប្រាក់ដែលបានវាយតំលៃ កាលបរិច្ឆេទនិងទីកន្លែងវាយតំលៃ ឈ្មោះអ្នកវាយតំលៃ

ង- អ្នកធានា ÷ ឈ្មោះ ស្ថានភាពហិរញ្ញវត្ថុ និងមូលនិធិផ្ទាល់សុទ្ធ

### III ព័ត៌មានសំរាប់វាយតំលៃពាក្យសុំឥណទាន

(ព័ត៌មានមួយចំនួនអាចមិនអនុវត្តចំពោះអ្នកសុំខ្ចីដែលជារូបវន្តបុគ្គល)

ក- ការវាយតំលៃ និងអនុសាសន៍របស់មន្ត្រីគ្រប់គ្រងគណនីឥណទាន និងនាយកចាត់ការ

ខ- ការអនុម័ត និងមូលដ្ឋាននៃការអនុម័តដោយគណៈគ្រប់គ្រង ឬគណៈកម្មការឥណទាន

គ- ការវិភាគគុណភាពផ្អែកលើ :

i- ព័ត៌មានរបស់អ្នកសុំខ្ចី

ii- សាវតាស្ដីពីទំនាក់ទំនងជាមួយអតិថិជន

iii- ព័ត៌មានស្ដីពីទំនាក់ទំនងប្រតិបត្តិការនៃក្រុមពាក់ព័ន្ធផ្សេងទៀតរបស់អ្នកសុំខ្ចីជាមួយធនាគារ

iv- ព័ត៌មានអំពីអ្នកសុំខ្ចីដែលទទួលបានពីគ្រឹះស្ថាននិងប្រភពផ្សេងៗ រួមមានការិយាល័យទំនាក់ទំនងរបស់ធនាគារ

v- ការវិភាគហានិភ័យក្នុងវិស័យ និងអាជីវកម្ម នៃការផ្តល់ឥណទាន

vi- ការប្រមូលផ្តុំឥណទានទៅលើអតិថិជនតែមួយ(បើសមស្រប)

ឃ- ការវិភាគបរិមាណផ្អែកលើៈ

i- ស្ថានភាពហិរញ្ញវត្ថុ និងការអនុវត្តន៍ ( គ្រាមុន គ្រាបច្ចុប្បន្ន និងតាមគំរោង)

ii- ផែនការអាជីវកម្ម ប្រភព និងការព្យាករណ៍លំហូរសាច់ប្រាក់សំរាប់បំពេញតំរូវការសងប្រាក់

ង- ប្រភពដើមទុន

ច- កិច្ចសន្យាផ្សេងៗ

ឆ- ការវាយតំលៃនិងតំលៃវត្ថុធានា

## IV ព័ត៌មានសំរាប់ពិនិត្យឥណទានឡើងវិញតាមគ្រា

(ព័ត៌មានមួយចំនួនអាចមិនអនុវត្តចំពោះអ្នកសុំខ្ចីដែលជារូបវន្តបុគ្គល)

ក- ការវាយតំលៃ និងអនុសាសន៍របស់មន្ត្រីពិនិត្យឥណទានឡើងវិញរួមមានៈ

i- ចំណាត់ថ្នាក់ និងកំរិតឥណទានដែលបានយល់ព្រម

ii- សវិធានធនសំរាប់ការខាតបង់

iii- ការប្រាក់ដែលព្យួរទុក

ខ- ការអនុម័ត និងមូលដ្ឋាននៃការអនុម័តសំរាប់ការផ្តល់ឥណទានជាថ្មី ការកែតំរូវខ្លឹមសារនិងលក្ខខ័ណ្ឌ និងការផ្លាស់ប្តូរចំណាត់ថ្នាក់ឥណទាន ។

គ- ព័ត៌មានដែលអាចទទួលបានចុងក្រោយស្តីពីៈ

i- ឥណទានកំពុងប្រើប្រាស់ រួមមានទ្រព្យអកម្មយថាហេតុ កិច្ចសន្យា និងប្រតិបត្តិការ ក្រៅតារាងតុល្យការដទៃទៀត

ii- ដំណើរការ និងការផ្តល់សេវាកម្មគណនី

iii- ឯកសារទំនាក់ទំនង និងរបាយការណ៍លទ្ធផលនៃការប្រជុំ (call report) ជាមួយអ្នកសុំខ្ចី និងការពិនិត្យដល់ទីកន្លែង

iv- ការវិភាគជាប្រចាំតាមគុណភាពផ្អែកលើព័ត៌មានថ្មីៗបំផុត រួមមានការផ្តល់យោបល់ពីសវនករផ្ទៃក្នុង និងពីខាងក្រៅដែលអាចទទួលបានអំពីអ្នកសុំខ្ចី

ឃ- ការវិភាគចរន្តតាមបែបបរិមាណផ្អែកលើព័ត៌មានហិរញ្ញវត្ថុ ការវាយតំលៃ និងការកំរិតតំលៃថ្មីៗបំផុត

ង- ព័ត៌មានស្តីពីដំណើរការគណនីរបស់ក្រុមដទៃទៀតដែលពាក់ព័ន្ធជាមួយអ្នកសុំខ្ចី ។

ច- វិភាគហានិភ័យក្នុងវិស័យនិងអាជីវកម្មនៃការផ្តល់ឥណទាន

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.05.54 Prakor

# PRAKAS

# ON

# Loan Policies, Procedures and Lending Authority

## The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996 promulgating the Law on the Organization and conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/0904/244 of 7 September 2004 on the appointment of His Excellency Chea Chanto as Governor of the National Bank of Cambodia;
- Pursuant to the agreement reached at the meeting of the senior officials of the NBC on 04 March 2005

## Decides

**Article 1.**

Every bank or financial institution shall conform to sound and prudent credit policies, practices and procedures in the granting of credit which shall be duly approved and reviewed by management and/or board of directors.

**Article 2.**

Every bank or financial institution shall establish:

i. written policies and procedures setting out its loan policies, procedures and limits of lending authority of its officers and/or credit committee and board of directors and that these be communicated to all personnel involved in the credit granting activities.

ii. credit files on all its borrowers which shall contain adequate and timely information and reliable as per appendix.

**Article 3.**

Loan policies, procedures and lending authority shall include, the requirements for credit analysis, approval process, periodic credit review procedures as per appendix, approving limits of officers and/or credit committee, collateral and documentation and other necessary information.

**Article 4.**

The General Direction, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 5.**

This Prakas shall have effect from the signing date.

Phnom Penh, March 10 , 2005

**The Governor**

**Signed and sealed: Chea Chanto**

cc:
- The Members of the Board of Directors
- The parties concerned as stated in Article 4
- File
- CM "for info"
- Administration of CM
  "for publication in the National Gazette"

**Appendix:** attached to
Prakas No. B7.05-054 Prokor
date March 10, 2005

# INFORMATION TO BE MAINTAINED IN CREDIT FILE

## (I) INFORMATION ON BORROWER

(a) Natural Persons ÷ Address, Contact address, Occupation, Employer, Salary/Income, Financial position/net worth and any other relevant information.

(b) Legal Persons ÷ Constitution (proprietorship, partnership) Business background and history, Organization structure, Management team/Directors, Shareholders/proprietor/partners, financial position and performance, and any other relevant information

## (II) INFORMATION ON CREDIT FACILITY

(a) Description of facility type (Overdraft, Revolving, Installment, amount, currency
(b) Purpose of facility
(c) Terms of facility ÷ limits, interest rates, repayment schedules, tenor/term, expiry dates
(d) Collateral ÷ Title deed number of collateral, location, types, valuation amount, valuation date and where applicable, name of appraiser
(e) Guarantors ÷ names, financial position and net worth

## (III) INFORMATION FOR APPRAISAL OF CREDIT APPLICATION

(Certain information would not be applicable for borrowers who are natural persons)

(a) Assessment and recommendations of account officer/manager
(b) Approval and basis of approval by management/credit committee
(c) Qualitative analyses based on:
- (i) Borrower Information
- (ii) History of relationship with customer
- (iii) Information on the banking relationship of other related groups of the borrower with the bank
- (iv) Information obtained on the borrower from other institutions and sources, including related offices of the bank
- (v) Analysis of industry and business risk
- (vi) Single customer concentration (if appropriate)

(d) Quantitative analyses based on:
   (i) Financial position and performance (previous, current and projected)
   (ii) Business plans, sources and cash flow forecast for meeting repayment requirements
(e) Capital resources
(f) Other commitments
(g) Collateral appraisal and value

## (IV) INFORMATION FOR PERIODIC CREDIT REVIEW

(Certain information would not be applicable for borrowers who are natural persons)

(a) Assessment and recommendations of credit review officer, including:
   (i) Credit grading/rating accorded
   (ii) Provision for losses
   (iii) Interest in suspense
(b) Approval and basis of approval for renewals; revision in terms and conditions; and changes in credit grading
(c) Latest available information on:-
   (i) Outstanding facilities utilized, including contingent liabilities, commitments and other off-balance sheet transactions
   (ii) Conduct and servicing of account
   (iii) Correspondences and call reports from meetings with borrowers and site visits
   (iv) Current qualitative analyses based on latest updated information including review comments from internal and external auditors where available on borrower,
(d) Current quantitative analyses based on latest updated financial information, appraisals and valuations
(e) Information on the account conduct of other related groups of the borrower
(f) Analysis of industry and business risk

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ១៧៦ ប្រក.កសក.

# ប្រកាស

## ស្តីពី

## អនុផលព្រៃឈើ

---

**រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១/២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Blvd Sangkat Tonle Basak Khan Chamkarmon, Phnom Penh, Cambodia Phone (023) 211 351/211 352 Fax (855) 23-217 320

## សម្រេច

**ប្រការ ១ :** ប្រកាសនេះកំណត់នូវចំណាត់ថ្នាក់ និង ប្រភេទនៃអនុផលព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ត្រូវបានចាត់ថ្នាក់ជាអនុផលព្រៃឈើ គឺរាល់សមាសភាគនៃធនធានព្រៃឈើ ដែលជាផលិតផលមិនមែនជាឈើហ៊ុបទាញចេញពីព្រៃឈើ រួមមាន ផលិតផលនៃរុក្ខជាតិមិនមែនឈើ ផលប្រមាញ់នៃសត្វព្រៃ និង ផលិតផលកែច្នៃរបស់វា រួមទាំងសេវាកម្មដែលផ្តល់ដោយព្រៃឈើ ។

**ប្រការ ២ :** អនុផលព្រៃឈើទាំងអស់ត្រូវបានចាត់ថ្នាក់ ដូចខាងក្រោម :

I- ឈើបន្ទាប់បន្សំ កូនឈើ និង អនុផលប្រើប្រាស់ក្នុងសំណង់ជាលក្ខណៈប្រពៃណី
II- ឈើថាមពល
III- ឫស្សី គាលព្រីក្ស ផ្តៅ វល្លិ
IV- អនុផលឱសថ
V- អនុផលក្រអូប
VI- អនុផលជ័រ
VII- អនុផលក្រមួន
VIII- អនុផលផ្តល់សារធាតុជ្រលក់ ឬ គីមី
IX- រុក្ខជាតិអាហារ
X- រុក្ខជាតិលំអ
XI- អនុផលឈើចម្លាក់
XII- អនុផលប្រើប្រាស់កែច្នៃដោយសិប្បកម្ម
XIII- ផលប្រមាញ់នៃសត្វព្រៃ
XIV- សេវាកម្មផ្តល់ដោយព្រៃឈើ ។

អនុផលព្រៃឈើដែលបានចាត់ថ្នាក់ក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៣ :** អនុផលព្រៃឈើណាដែលមិនទាន់បានកំណត់ និង ចាត់ថ្នាក់ក្នុងប្រការ២ ខាងលើ រដ្ឋបាលព្រៃឈើត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីចាត់ថ្នាក់ជាបន្តបន្ទាប់តាមការចាំបាច់ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អាចពិនិត្យឡើងវិញលើចំណាត់ថ្នាក់ និង ប្រភេទអនុផលព្រៃឈើដែលបានកំណត់ក្នុងប្រកាសនេះ តាមការចាំបាច់ ។

**ប្រការ ៤ :** ប្រកាស ឬ សេចក្ដីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី.១៤..ខែ៣.....ឆ្នាំ ២០០៥

រដ្ឋមន្ត្រី

ច័ន្ទ សារុន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ...១៣៦....ប្រក.កសក. ចុះថ្ងៃទី..១២.. ខែ...មីនា... ឆ្នាំ ២០០៥

# ចំណាត់ថ្នាក់ និង ប្រភេទអនុផលព្រៃឈើ

## I - ឈើបន្ទាប់បន្សំ កូនឈើ និង អនុផលប្រើប្រាស់ក្នុងសំណង់ជាលក្ខណៈប្រពៃណី មានជាអាទិ៍ :

១- សសរមូលគ្រប់ប្រភេទ ទំហំ ១៥-២៥ សម.
២- ដើមព្រាលព្រៃ
៣- បង្គោលក្រាក់
៤- បង្គោលស្នាច់
៥- បង្គោលឈើប្រភេទផ្សេងទៀត
៦- ស្បូវ
៧- កណ្តុបស្បូវ
៨- ស្លឹកខ័ណ្ឌមា
៩- ស្លឹករុក្ខជាតិព្រៃផ្សេងទៀតដែលអាចធ្វើកណ្តុបស្លឹកបាន
១០- កូនឈើប្រឡៅមូលគ្រប់ប្រភេទទំហំតលក្រោម ២០សម.
១១- ដើមកក់
១២- ដើមកញ្ចូត
១៣- ដើមប្រើ
១៤- ដើមបបោស
១៥- ដើមត្រែង
១៦- ដើមស្ពា
១៧- ស្លឹកទ្រាំង
១៨- សំបកឈើព្រៃដែលអាចគាបធ្វើជិបូល ឬ ជញ្ជាំងបាន

## II - ឈើថាមពល មានជាអាទិ៍ :

១- អុសចម្រុះប្រភេទ
២- ធ្យូងចម្រុះ
៣- គ្រឿងឆេះផ្សេងទៀតដែលកែច្នៃពីអនុផល ព្រៃឈើ ឬ កាកសំណល់ឈើ

## III - ឫស្សី ផាលព្រឹក្ស ផ្តៅ វល្លិ មានជាអាទិ៍ :

### ក- ឫស្សី :

១- ឫស្សីឃ្លៃ
២- ឫស្សីឃ្លីច
៣- ឫស្សីថ្ងរ
៤- ឫស្សីទ្រទំមាន់
៥- ឫស្សីទ្រទំមាន់ភ្នំ
៦- ឫស្សីពីងពង់ថ្លោល
៧- ឫស្សីពីងពង់ស្ករ
៨- ឫស្សីពកធំ
៩- ឫស្សីពកតូច
១០- ឫស្សីព្រៃ
១១- ឫស្សីព្រេចចន្ទូញ
១២- ឫស្សីព្រេចស្បាត
១៣- ឫស្សីរលោកធំ
១៤- ឫស្សីរលោកសាញ់
១៥- ឫស្សីរលោកតូច
១៦- ឫស្សីលរ
១៧- ឫស្សីអាមិញ
១៨- ឫស្សីព្រៃផ្សេងទៀត

**ខ- តាលព្រឹក្ស :**

១- ចាក
២- ជក់
៣- ដូងព្រះ
៤- តាឱន
៥- ទន្សែ
៦- ទ្រាំង
៧- ទ្រៀក
៨- ផ្អាវ
៩- ពីង (តឹង-ចាលា)
១០- ស្លាព្រៃ
១១- ស្លាខ្មៅ
១២- ស្លាឆ្លាប់
១៣- ស្លាស្វាប
១៤- តាលព្រឹក្សផ្សេងទៀត

**គ- ផ្ដៅ :**

១- ផ្ដៅក្រែក
២- ផ្ដៅឈ្វាំង
៣- ផ្ដៅជីបង
៤- ផ្ដៅត្រែស
៥- ផ្ដៅទឹក
៦- ព្រះផ្ដៅ
៧- ផ្ដៅយ៉ាក
៨- ផ្ដៅរពាក់
៩- ផ្ដៅសោម
១០- ផ្ដៅស្នោ (ផ្ដៅអារ៉ែក ផ្ដៅមាស)
១១- ផ្ដៅស្វា
១២- ផ្ដៅសឹង
១៣- ផ្ដៅអាចម៍មាន់
១៤- ផ្ដៅផ្សេងទៀត

**ឃ- វល្លិ :**

១- វល្លិកញ្ជ្រិល
២- វល្លិកន្ទិតអាល
៣- វល្លិកាដាត
៤- វល្លិកំបោរ
៥- វល្លិក្តួច
៦- វល្លិក្រួច
៧- វល្លិក្រវ៉ាញ (វល្លិចេកទុំ)
៨- វល្លិខ្មែ
៩- វល្លិខ្មែងពណិ
១០- វល្លិខ្មែង
១១- វល្លិខ្នាញ់
១២- វល្លិខ័ណ្ឌមាញ៉ី
១៣- វល្លិខ្នាយមាន់
១៤- វល្លិខ្នាយមាន់ស្បាត
១៥- វល្លិខ្ទួត
១៦- វល្លិខ្សួស
១៧- វល្លិគុយ
១៨- វល្លិគ្រួ
១៩- វល្លិឃ្លាយ
២០- វល្លិចារ
២១- វល្លិចេកទុំ
២២- វល្លិឆ្កាល់មាន់ស្បាត
២៣- វល្លិឆ្នួត
២៤- វល្លិជ័របាញ់
២៥- វល្លិជណ្ដើរស្វា
២៦- វល្លិជុច
២៧- វល្លិជុយ
២៨- វល្លិដំឡូងត្រែង
២៩- វល្លិដំឡូងខ្មៀន
៣០- វល្លិដំឡូងជ្រូក

៣១- វល្លិដំឡូងស្រ
៣២- វល្លិដំឡូងស្បា
៣៣- វល្លិដំឡូងទឹក
៣៤- វល្លិជីស
៣៥- វល្លិដោះគុណ
៣៦- វល្លិដែក ( វល្លិព្រហ្មលោក)
៣៧- វល្លិត្នោត
៣៨- វល្លិត្របែងជើងក្អែង
៣៩- វល្លិត្រី
៤០- វល្លិតាអើក
៤១- វល្លិតាអាញ់
៤២- វល្លិតាលុង
៤៣- វល្លិតាលីងក្រហម
៤៤- វល្លិតាលីងស
៤៥- វល្លិទ្រាលដោះក្របី
៤៦- វល្លិទ្រាលស្វា
៤៧- វល្លិទំពាំងបាយជូរ
៤៨- វល្លិទឹក
៤៩- វល្លិធ្នូក
៥០- វល្លិបណ្ដូលពេជ្រ
៥១- វល្លិប្រេងក្រហម
៥២- វល្លិព័ទ្ធ
៥៣- វល្លិពងក្ដស្វា
៥៤- វល្លិពុលឯក
៥៥- វល្លិពុម្ព ( វល្លិអំពុងស្រមោជ)
៥៦- វល្លិពុម្ពមាន់
៥៧- វល្លិព្រៃស
៥៨- វល្លិព្រះតាហ៊ឹង
៥៩- វល្លិមហាមេឃ
៦០- វល្លិយាវខ្មៅ
៦១- វល្លិយាវស
៦២- វល្លិរមៀត
៦៣- វល្លិរមូលភ្លើង
៦៤- វល្លិលែនពេន
៦៥- វល្លិលក្ខ
៦៦- វល្លិស្មៀវ
៦៧- វល្លិស្លែងជងដាង
៦៨- វល្លិស្លែងវារ
៦៩- វល្លិស្រឡៅអន្ទេរ
៧០- វល្លិសង្ឃុត
៧១- វល្លិសណ្ដា
៧២- វល្លិស្អូក
៧៣- វល្លិអែម
៧៤- វល្លិអន្ទ្រង
៧៥- វល្លិអាវនរ
៧៦- វល្លិអាវក្រពើ
៧៧- វល្លិអង្កត់ក្រហម ( ជ្រៃជ្រួយ)
៧៨- វល្លិអង្កត់សរ
៧៩- វល្លិអង្គញ
៨០- វល្លិអន្ទង់
៨១- វល្លិអន្ទង់ម៉ា
៨២- វល្លិអំពិល
៨៣- វល្លិអំពុស
៨៤- វល្លិជៀងទៀត

## IV - អនុផលឱសថ មានជាអាទិ៍ :

### ក- ប្រើសម្រាប់មនុស្ស

១- កញ្ចុះដង្កូវ ( ស្លឹក)
២- កញ្ជើបាយដាច ( គ្រាប់ ដើម និងឫស)
៣- កណ្ដោល ( សំបក)
៤- កណ្ដាប់ចង្កេះ ( ដើម)
៥- កន្ទ្រំជារី ( ដើម និងមើម)
៦- កន្ទ្រោក ( ស្លឹក សំបក និងឫស)

៧- កន្ទ្រោកជី (ដើម និងឫស)
៨- កន្ទ្រោកខ្មោច (ស្លឹក)
៩- កន្ទ្រោករលាយខួរ(ស្លឹក)
១០- កន្ទើតចចក (ដើម)
១១- កន្ទេចអាល (ស្លឹក)
១២- កន្ទុតព្រៃ (សំបក)
១៣- កន្ទុយដី (ស្លឹក)
១៤- កន្ទុយក្រោក(ឫស)
១៥- កន្ទុយល្ងេ (សំបក)
១៦- កន្ទុយកំប្រុក (ដើម និងស្លឹក)
១៧- កន្ទុយត្រកួត (ផ្កា និងឫស)
១៨- កន្ធំថេតព្រៃ (ផ្លែ)
១៩- កុលាបភ្នំ (ឫស)
២០- កុមារពេជ្រ (មើម)
២១- កោងកាងភ្នំ(សំបក)
២២- កំពាន (ឫស)
២៣- កំពីងរាជ (ស្លឹក និងឫស)
២៤- កំរើកគុម្ព (ឫស)
២៥- កំភ្លាង (សំបក ឫស)
២៦- ការទេះ (ស្លឹក និងផ្កា)
២៧- ការទេះដង(ស្លឹក)
២៨- ក្តាំងបាយ (ឫស)
២៩- ក្បាលកន្លង់ (សំបក)
៣០- ក្បាលរុយ (ស្លឹក ដើម និងឫស)
៣១- ក្បុកដី (ស្លឹក)
៣២- ក្រាមរមាស (សំបក)
៣៣- ក្រាយ(សំបក)
៣៤- ក្រពុលបាយ (ស្លឹក និងសំបក )
៣៥- ក្របាប់ស្វែងពីរ (ផ្លែ)
៣៦- ក្របៅផ្លែធំ (គ្រាប់)
៣៧- ក្របៅផ្លែតូច (គ្រាប់)
៣៨- ក្រពេន (ឫស)
៣៩- ក្រពេនទឹក(ស្លឹក)
៤០- ក្រកោដី (គ្រាប់)
៤១- ក្រញូងក្រហម (ស្លឹក និងឫស)
៤២- ក្រគី (គ្រាប់)
៤៣- ក្រឡាំពៃ (ស្លឹក ផ្កា ផ្លែ និងឫស)
៤៤- ក្រចព្រៃ (ដើម)
៤៥- ក្រវាញ (គ្រាប់)
៤៦- កួន (ឫស)
៤៧- កួត( គ្រាប់ )
៤៨- ខ្ទឹង (ស្លឹក និងគ្រាប់)
៤៩- ខ្ទម្ពធំ (ឫស)
៥០- ខ្ទម្ពទឹក (សំបក និងឫស)
៥១- ខ្ទម្ពគោក (សំបក)
៥២- ខ្នាញ់ (ស្លឹក)
៥៣- ខ្នែងពណិ (គ្រាប់)
៥៤- ខ្នាញ់ក្លាម(ឫស )
៥៥- ខ្ទុង (ឫស)
៥៦- ខ្នារ (ឫស )
៥៧- ខ្នារបន្លា (ស្លឹក)
៥៨- គគីរ (សំបក)
៥៩- គុមក្មាត់ (ស្លឹក)
៦០- គ្រើល (សំបក)
៦១- គែស្រលក (ស្លឹក និងដើម)
៦២- គោមួយ (សំបក និងឫស)
៦៣- គ្រុង (ឫស)
៦៤- ឃ្លែ (ស្លឹក និងផ្លែ)
៦៥- ឃ្មុំ (ទឹក)
៦៦- ងប់ (ឫស)
៦៧- ចង្កង់ស្វា (ផ្កា)
៦៨- ចង្រង់ស្វាធំ (ផ្លែ)
៦៩- ចន្ទន៍ក្រស្នា (ដើម)
៧០- ចាន់ព្រៃ (ផ្លែផ្កា)

៧១- ចារ (ដើម និងគ្រាប់)
៧២- ចែង (ស្លឹក)
៧៣- ចំប៉ីព្រៃ (ស្លឹក និងផ្កា)
៧៤- ចំបក់ប្រាំង (សំបក)
៧៥- ចំរៀក (សំបក)
៧៦- ច្រេស (សំបក គ្រាប់ និងផ្កា)
៧៧- ឆាំឆា (សំបក ផ្កា និងឫស)
៧៨- ឆ្កែស្រែង (សំបក និងដើម)
៧៩- ឆ្អាល់មាន់ (ឫស)
៨០- ឆ្អឹងពស់ភ្នំ (ដើម)
៨១- ជណ្តើរស្វា (ដើម និង សំបក)
៨២- ជណ្តើរស្វាតូច (ដើម)
៨៣- ជន្លង់ (ស្លឹក និងគ្រាប់)
៨៤- ជន្លួស (ត្រួយ និងឫស)
៨៥- ជើងគោថ្កាល (ស្លឹក)
៨៦- ជំពូព្រែក (សំបក)
៨៧- ជ្រៃក្រឹម (សំបក ឫស និងជ័រ)
៨៨- ជ័យភ្នា (ស្លឹក និងដើម)
៨៩- ឈាមអន្ទង់ (ជ័រ)
៩០- ឈូកវត្តព្រៃ (ដើម)
៩១- ឈើជ័រ (ស្លឹក)
៩២- ឈើអែម (ស្លឹក និងសំបក)
៩៣- ឈើកែវ (ស្លឹក និងផ្លែ)
៩៤- ឈើថ្មលឿង (សំបក)
៩៥- ឈើក្រុងស្វា (ដើម និងឫស)
៩៦- ឈើរមាស់ (ជ័រ)
៩៧- ឈើស្រូលក្រហម (ស្លឹក ដើម និងឫស)
៩៨- ឈើស (សំបក)
៩៩- ឈើទាល (សំបក)
១០០- ឈើទាលគ្រាង (ឫស)
១០១- ឈើទិព្វ (ឫស)
១០២- ឈ្នឹក (សំបក)
១០៣- ញរព្រៃ (ឫស)
១០៤- ញញួរឃ្លាយ (ស្លឹក និងឫស)
១០៥- ញិញបាត (ស្លឹក និងផ្កា)
១០៦- ដង្កោ (ផ្លែ)
១០៧- ដង្ហិម (ស្លឹក)
១០៨- ដង្ហិត (ស្លឹក និងដើម)
១០៩- ដង្ហិតខ្មោច (ស្លឹក និងគ្រាប់)
១១០- ដកខឹម (ឫស)
១១១- ដីប៊ូ (ផ្លែ)
១១២- ដីសព្រៃ (មើម)
១១៣- ដូងព្រះ (ស្លឹក និងសំបក)
១១៤- ដូងស្បាត (ផ្កា និងឫស)
១១៥- ដៃរហាត់ (ឫស)
១១៦- ដៃខន់ (ស្លឹក គ្រាប់ និងឫស)
១១៧- ដីប្រាំដក (ឫស)
១១៨- ដោះគន់ (ស្លឹក គ្រាប់ និងឫស)
១១៩- តាឡាត់ (គ្រាប់)
១២០- ត្បាល់កិន (ស្លឹក សំបក និង គ្រាប់)
១២១- ត្នោង (ស្លឹក និងឫស)
១២២- ត្រាង (ជ័រ)
១២៣- ត្រាំកង់ (ដើម និងជ័រ)
១២៤- ត្រដិត (ឫស)
១២៥- ត្រចៀកក្រាញ់សមុទ្រ (ស្លឹក)
១២៦- ត្រសៀក (ស្លឹក និងឫស)
១២៧- ត្រថុក (មើម)
១២៨- ត្រុំ (ឫស)
១២៩- ត្រមូងសេក (សំបក)
១៣០- ត្រមូច (ឫស)
១៣១- ត្រុំព្រៃ (ស្លឹក និងដើម)
១៣២- ត្រុំស្វា (ឫស)
១៣៣- ត្រយឹង (ស្លឹក)
១៣៤- ថ្កូវ (ដើម និងសំបក)

១៣៥- ថ្នាន់ ( សំបក )
១៣៦- ថ្នាំក្អែក ( ផ្លែ )
១៣៧- ថ្មទាប់ ( គ្រាប់ )
១៣៨- ថ្មើមទឹក ( ស្លឹក និងឫស )
១៣៩- ថ្នួន ( ជ័រ )
១៤០- ទន្ទ្រានព្រៃ ( ផ្លែ )
១៤១- ទន្លាប់ទេស ( ស្លឹក )
១៤២- ទឹកដោះ ( ក្អែកមាន់ ) ( ស្លឹក ដើម និង ជ័រ )
១៤៣- ទឹកដោះព្រៃ ( ដើម ស្លឹក សំបក និងឫស )
១៤៤- ទឹកដោះខ្លា ( ជ័រ )
១៤៥- ទេព្វីរតូច ( ស្លឹក និងដើម )
១៤៦- ទំពាំងបាយជូរព្រៃ ( ឫស )
១៤៧- ទំពូង ( ស្លឹក និងឫស )
១៤៨- ទ្រាលស្វា ( ឫស )
១៤៩- ទ្រមែង ( សំបក )
១៥០- ទ្រនំកំភេម ( ស្លឹក និងឫស )
១៥១- ទ្រនំកំភេមតូច ( ស្លឹក និងឫស )
១៥២- ធ្នង់ ( សំបក )
១៥៣- ធ្នង់ឈាមមាន់ ( ជ័រ និងឫស )
១៥៤- ធ្មៃ ( ស្លឹក និងឫស )
១៥៥- ធ្មៃព្រៃ ( ផ្កា )
១៥៦- ធ្មេញត្រី ( ដើម )
១៥៧- ធ្លាយ ( ឫស )
១៥៨- នាងខ្មៅ ( ស្លឹក និងឫស )
១៥៩- នាងស ( សំបក )
១៦០- បញ្ជើក្អែក ( ស្លឹក និងដើម )
១៦១- បញ្ជើក្អែកធំ ( ដើម )
១៦២- បញ្ជើក្អែកគ្រប់ប្រភេទឈើ ( ដើម )
១៦៣- បង្វល ( ស្លឹក )
១៦៤- បង្គី ( ឫស )
១៦៥- បន្ទាក្បាលយក្ស ( ដើម )
១៦៦- បន្ទាស្អិត ( ផ្លែ និង គ្រាប់ )
១៦៧- បណ្តូលពេជ្រ ( ដើម និងឫស )
១៦៨- បំប្រើស ( ឫស )
១៦៩- បំប្រេក ( ស្លឹក )
១៧០- ប៉ាតព្រុម ( ស្លឹក )
១៧១- បាបាត ( គ្រាប់ និងឫស )
១៧២- បាតឃ្មោក ( ស្លឹក និងគ្រាប់ )
១៧៣- បាយដំណើប ( ផ្លែ )
១៧៤- បាយក្រៀម ( ឫស )
១៧៥- បាយក្រៀមឈ្មោល ( ស្លឹក )
១៧៦- បាយក្តាំង ( ឫស )
១៧៧- បាយម៉ាត ( ស្លឹក )
១៧៨- បូព្រឹក្ស ( ដើម )
១៧៩- បើស ( ស្លឹក )
១៨០- ប៉េងប៉ោះស្រោម ( ស្លឹក និងឫស )
១៨១- បេង ( សំបក )
១៨២- ប្របួយ ( ឫស )
១៨៣- ប្រភេញឈ្មោល ( សំបក )
១៨៤- ប្រមោយដំរី ( ស្លឹក ដើម និងឫស )
១៨៥- ប្រង់សមុទ្រ ( មើម )
១៨៦- ប្រក់ផ្លែ ( ស្លឹក ដើម និងឫស )
១៨៧- ប្រសាកញី ( សំបក )
១៨៨- ប្រទាលឫស ( សំបក និងឫស )
១៨៩- ព្រោះស្វា ( ស្លឹក និងមើម )
១៩០- ផ្ទឹក ( ផ្សិត )
១៩១- ផ្ទឹក ( សំបក )
១៩២- ផ្ទី ( មើម )
១៩៣- ផ្ទក់ក្រហម ( ដើម )
១៩៤- ផ្គៅស្វា ( ដើម )
១៩៥- ផ្គៅស្វាស៊ីស្លឹក ( ដើម )
១៩៦- ផ្លាង ( ស្លឹក និងដើម )
១៩៧- ផ្ការ ( សំបក និងឫស )
១៩៨- ពពាលខែឈ្មោល ( សំបក )

១៩៩- ពញ្ញាធំ (ស្លឹក សំបក និងឫស)
២០០- ពពេល (សំបក)
២០១- ពន្លៃ (មើម)
២០២- ពភ្លា (ឫស)
២០៣- ពង្រ (សំបក)
២០៤- ពិកា (សំបក និងឫស)
២០៥- ពីងចាប (ឫស)
២០៦- ពុកឆ្មា (ស្លឹក និងដើម)
២០៧- ពុកឆ្មារឈ្មោល (ឫស)
២០៨- ពុលឯក (ដើម)
២០៩- ពូចជូរ (ស្លឹក)
២១០- ពុំពែន (សំបក)
២១១- ពុំសែន (សំបក)
២១២- ព្រាលខ្យាច់ (ឫស)
២១៣- ព្រះភ្លៅ (សំបក)
២១៤- ព្រះអន្លក់ (ស្លឹក និងឫស)
២១៥- ព្រំបន្លា (ឫស)
២១៦- ភិកមន (ស្លឹក និងឫស)
២១៧- ភ្សៀវ (ដើម)
២១៨- ភ្លៅ (ស្លឹក និងផ្លែ)
២១៩- ភ្លែកព្រាប (ស្លឹក និងសំបក)
២២០- ភ្លៅមាន់ (ឫស)
២២១- ភ្លាំង (ស្លឹក)
២២២- ភ្លូងជូរ (ឃ្លាស) (ស្លឹក)
២២៣- ភ្លូបាត (សំបក និងឫស)
២២៤- ភ្លូធំ (សំបក)
២២៥- មន្ត្រី ឫ ភ្លៅនាង (សំបក)
២២៦- មុខឈ្លាង (ស្លឹក ឫស)
២២៧- មេកង (ឫស)
២២៨- ម្កាក់ព្រៃ (សំបក និងជ័រ)
២២៩- ម្លុលពេជ្រ (ស្លឹក)
២៣០- ម្លុលប្រាក់ (ឫស)
២៣១- ម្ទូរព្រឹក (គ្រាប់)
២៣២- ម្ទូរព្រឹកព្រៃ (គ្រាប់)
២៣៣- ម្រេចទន្សាយ (ស្លឹក)
២៣៤- ម្រាមនាង (ដើម)
២៣៥- ម្រះព្រៅភ្នំ (ប្រេង)
២៣៦- ម្អមភ្នំ (ស្លឹក)
២៣៧- រពាក់ (ឫស)
២៣៨- រមៀតស (ឫស)
២៣៩- រយោង (សំបក)
២៤០- រង្គ (ជ័រ)
២៤១- រកា (សំបក ផ្កា និងគ្រាប់)
២៤២- រកាវារ (ស្លឹក)
២៤៣- រលោយឈាម (ឫស)
២៤៤- រលួសបាយ (ស្លឹក សំបក គ្រាប់ និងឫស)
២៤៥- រាជដាស (ឫស)
២៤៦- រាជត្ពីស (ឫស)
២៤៧- រាក់បាត (ឫស)
២៤៨- រៃទឹក (ដើម)
២៤៩- រោតក្រហម (ដើម)
២៥០- រោតស (ដើម)
២៥១- រំចេកភ្នំ (ស្លឹក)
២៥២- រំចេកសមុទ្រ (ស្លឹក)
២៥៣- រំដេញមាស (ដើម និងឫស)
២៥៤- រំយោលភ្នំ (ស្លឹក ផ្កា និងឫស)
២៥៥- រំលោយស្នង (សំបក និងគ្រាប់)
២៥៦- រាំង (ស្លឹក និងសំបក)
២៥៧- រាំងទឹក (សំបក និងឫស)
២៥៨- លាជផ្ទុះ (ស្លឹក និងឫស)
២៥៩- លៀប (ជ័រ)
២៦០- លំពាន់ (ឫស)
២៦១- លំពស់ដែក (ឫស)
២៦២- លាំងដៃ (ជ័រ)

២៦៣- លាំងដៃតូច (ឫស)
២៦៤- ល្ហុ (ស្លឹក)
២៦៥- ល្ហាជី (ដើម និងឫស)
២៦៦- ល្ហាព្រៃ (ស្លឹក)
២៦៧- វល្លិកក្រើក (ឫស)
២៦៨- វល្លិក្បុង (ដើម)
២៦៩- វល្លិក្អាញ់ (ស្លឹក)
២៧០- វល្លិកន្ទើតចាស់ (ដើម)
២៧១- វល្លិកំបោរ (ដើម)
២៧២- វល្លិកំបោរភ្នំ (សំបក)
២៧៣- វល្លិកួយ (ដើម)
២៧៤- វល្លិក្រពាត់ឈ្លាង
២៧៥- វល្លិក្រអោម (ស្លឹក)
២៧៦- វល្លិប្រាក់កាក់
២៧៧- វល្លិខ្យុស (ស្លឹក និងសំបក)
២៧៨- វល្លិគុយ (ដើម និងជ័រ)
២៧៩- វល្លិចារ (ស្លឹក និងដើម)
២៨០- វល្លិចេកទុំ (ស្លឹក)
២៨១- វល្លិឆ្លូតគ្រាប់ (ស្លឹក និងដើម)
២៨២- វល្លិត្រោក (ឫស)
២៨៣- វល្លិត្លើក (គ្រាប់)
២៨៤- វល្លិត្រជិត (ដើម)
២៨៥- វល្លិត្រស់ (សំបក និងឫស)
២៨៦- វល្លិទៀន (ស្លឹក)
២៨៧- វល្លិទាល់ព្រៃ (ស្លឹក)
២៨៨- វល្លិទាល់ស៊ីស្លឹក (ស្លឹក)
២៨៩- វល្លិធ្មេញត្រី (ស្លឹក)
២៩០- វល្លិធ្មង់កញ្ចុះ (ស្លឹក)
២៩១- វល្លិនោមជីវ (ជ័រ)
២៩២- វល្លិជោម (ស្លឹក និងដើម)
២៩៣- វល្លិភ្នូ (ឫស)
២៩៤- វល្លិមៀន (ស្លឹក)
២៩៥- វល្លិម្ទេសព្រៃ (ផ្កា)
២៩៦- វល្លិមាស (ដើម)
២៩៧- វល្លិមហាមេឃ (ដើម)
២៩៨- វល្លិរមៀតស (ផ្លែ)
២៩៩- វល្លិលិនដីរ (ដើម)
៣០០- វល្លិស្នែងគោ (ឫស)
៣០១- វល្លិស្រកាពង្រូល (ដើម និងឫស)
៣០២- វល្លិខ្សែឡូ (ដើម)
៣០៣- វល្លិអង្កត់ (សំបក និងជ័រ)
៣០៤- វល្លិអំពិល (គ្រាប់ ឫស)
៣០៥- សង្កែភ្លើង (សំបក)
៣០៦- សណ្តែកព្រៃ (ស្លឹក ដើម)
៣០៧- សណ្តែកព្រៃសមុទ្រ (គ្រាប់)
៣០៨- សណ្តែកក្តិង្គ (គ្រាប់ និងស្លឹក)
៣០៩- សក់សេះ (គ្រាប់)
៣១០- សម្បុរល្វែង (សំបក)
៣១១- សាគូចាម (ស្លឹក)
៣១២- សាគូភ្នំ (ឫស)
៣១៣- សាមសិប (ឫសមើម)
៣១៤- សិរសោច (ស្លឹក ដើម និង ឫស)
៣១៥- សិរមាន់ស (គ្រាប់)
៣១៦- សុក្រំ (ផ្សិត)
៣១៧- សុក្រំ (សំបក)
៣១៨- សូភី (សំបក)
៣១៩- សូស (ឫស)
៣២០- សេដាព្រៃ (សំបក ឫស និង ជ័រ)
៣២១- សំព័រឈើ (ស្លឹក ផ្លែ សំបក ដើម និងឫស)
៣២២- សំរោងស្វា (គ្រាប់)
៣២៣- សំរក (ស្លឹក)
៣២៤- ស្តៅខ្មោច (ស្លឹក)
៣២៥- ស្អុកស្អុរ (សំបក)
៣២៦- ស្នោអំបោះ (ដើម)

៣២៧- ស្លែងគោ ( ឫស)
៣២៨- ស្លែងក្របី ( ស្លឹក)
៣២៩- ស្លែងវិជ្ជូល ( ស្លឹក ផ្កា និងឫស)
៣៣០- ស្វាយដែល ( ឫស)
៣៣១- ស្បែង ( ដើម)
៣៣២- ស្បូវ ( ឫស)
៣៣៣- ស្លង់ ( សំបក)
៣៣៤- ស្មៅភ្លើង ( ដើម)
៣៣៥- ស្មៅវែទឹក
៣៣៦- ស្មៅមមាំង ( ដើម និងឫស)
៣៣៧- ស្មៅផ្កាថ្ម
៣៣៨- ស្មៅរាំងទឹក ( ស្លឹក)
៣៣៩- ស្មៅប្រមាត់មនុស្ស ( ដើម និងឫស)
៣៤០- ស្មៅប្រមាត់ថ្ម
៣៤១- ស្មៅក្រជៀប ( ឫស)
៣៤២- ស្មៅស្នាច់ទឹក ( ស្លឹក និងដើម)
៣៤៣- ស្មៅសន្សើមដូច
៣៤៤- ស្មៅត្មាតទន្ទ្រាន
៣៤៥- ស្មៅទំពាំងបារាំង ( ឫស)
៣៤៦- ស្មៃសៀម ( សំបក និងឫស)
៣៤៧- ស្នាច់ ( ស្លឹក)
៣៤៨- ស្នាក្របី ( គ្រាប់)
៣៤៩- ស្រងល់ ( ឫស)
៣៥០- ស្រល់ ( ជ័រ)
៣៥១- ស្រម៉ពិភេទក៏ ( ផ្លែ)
៣៥២- ស្រូលស ( ជ័រ)
៣៥៣- ស្លែង ( សំបក និងគ្រាប់)
៣៥៤- ស្នាប៉ាង ( ស្លឹក)
៣៥៥- ស្នាប៉ាងស្លឹកវែក ( ស្លឹក)
៣៥៦- ស្វាយព្រៃ ( សំបក)
៣៥៧- ស្វាយកណ្តុរ ( សំបក)
៣៥៨- ហង្សធំ ( ឫស)
៣៥៩- ហើមធំ ( សំបក)
៣៦០- អញ្ចាញ ( ស្លឹក ដើម និងឫស)
៣៦១- អង្គ្រែមអង្គ្រ ( គ្រាប់ សំបក និង ឫស )
៣៦២- អង្គោល ( ជ័រ)
៣៦៣- អង្គោលបន្លា ( ដើម និង ជ័រ)
៣៦៤- អង្គ្រែដែក ( ដើម)
៣៦៥- អង្គាញ់ ( ដើម)
៣៦៦- អម្ពិលខ្មែរ ( ដើម)
៣៦៧- អន្លងស ( ស្លឹក និងឫស)
៣៦៨- អណ្តាតគោ ( ឫស)
៣៦៩- អណ្តាតឆ្កែ ( ស្លឹក ផ្កា និងដើម)
៣៧០- អន្លង់ស ( ស្លឹក ដើម និងឫស)
៣៧១- អន្លង់ទាត់ ( ឫស)
៣៧២- អណ្តូងព្រះ ( ស្លឹក និងគ្រាប់)
៣៧៣- អាវលាវ ( ដើម និងសំបក)
៣៧៤- អំបែងថ្ងៃ ( សំបក និងឫស)
៣៧៥- ឥសីផ្សំស្រេច ( ស្លឹក ដើម និងឫស)
៣៧៦- ឥន្ទនេល ( ស្លឹក សំបក និងផ្លែ)
៣៧៧- អនុផលឱសថសំរាប់មនុស្សផ្សេងទៀត

**ខ- ប្រើសម្រាប់បសុសត្វ**

១- ក្តួច ( មើម)
២- ឈើទាល ( សំបក)
៣- បេង ( សំបក)
៤- រពាក់ ( ឫស)
៥- ស្តៅភ្នំ ( សំបក)
៦- ស្មៅអណ្តាតឆ្កែ
៧- អំព្រៅ ( ស្លឹក)
៨- អនុផលឱសថសំរាប់បសុសត្វផ្សេងទៀត

**V - អនុផលក្រអូប មានជាអាទិ៍ :**

១- កែនលេខ ១
២- កែនពិសេស
៣- ក្រពុលចាយ(សំបក)
៤- ខ្ទឹមចន្ទន៍ក្រស្នា ( កាកចម្រាញ់)
៥- ខ្ទឹមចន្ទន៍ក្រស្នា ( ប្រេងចម្រាញ់)
៦- ចន្ទន៍ក្រស្នា ( ដើម)
៧- ចន្ទន៍ក្រស្នា ( ចំណាំងដើម)
៨- ចន្ទន៍ក្រស្នា ( ម្សៅ)
៩- តុ
១០- ទេពីរូ ( ប្រេងចម្រាញ់)
១១- ជ័រខ្វាន់ថ្មី
១២- ជ័រខ្វាន់ចាស់ " វង់លើ "
១៣- ម្រះព្រៅភ្នំ( ប្រេងចម្រាញ់)
១៤- យាងបោង( សំបក)
១៥- ប្រទាក់(ស្លឹក)
១៦- ឡាំលេខ ១
១៧- ឡាំលេខ ២
១៨- រុក្ខជាតិ និង អនុផលក្រអូបផ្សេងទៀត ។

**VI - អនុផលជ័រ មានជាអាទិ៍ :**

១- ជ័រខ្មៅ
២- ជ័រចុង
៣- ជ័រប្រេងម៉ាស់
៤- ជ័រត្បែង
៥- ជ័រទឹកថ្លា
៦- ជ័រទឹកខាប់
៧- ជ័រទី
៨- ជ័រថ្នឹក
៩- ជ័រផ្ទុង
១០- ជ័រពពេល
១១- ជ័ររង្គ
១២- ជ័រល័ក្ខ
១៣- ជ័រស្រល់
១៤- ចន្លុះ ឬ ត្រោល
១៥- ម្រក្សណ៍
១៦- អនុផលជ័ររុក្ខជាតិផ្សេងទៀត ។

**VII - អនុផលក្រមួន មានជាអាទិ៍ :**

១- ក្រមួនឃ្មុំ
២- ក្រមួនព្រួត
៣- ក្រមួនម្រោម
៤- អនុផលផ្តល់ក្រមួនផ្សេងទៀត ។

**VIII — អនុផលផ្តល់សារធាតុជ្រលក់ ឬ គីមី មានជាអាទិ៍ :**

១- កកោះ( សំបក)
២- កន្ទួតព្រៃ ( សំបក ស្លឹក និងផ្លែ)
៣- កណ្តោល ( សំបក)
៤- កោងកាង( សំបក)
៥- ក្រឡាញ់ ( សំបក)
៦- ក្រមួនចំបក់ ( ដើម និង ស្លឹក)
៧- ខ្នុរព្រៃ ( សំបក)
៨- ឃ្លេ( ដើម)
៩- ចាន់ទំពាំង ( សំបក)
១០- ជន្លង់ ( គ្រាប់)
១១- ឈាមអន្ទង់ ( ដើម)
១២- ដង្ហិតខ្មោច( សំបក)
១៣- ដង្កោ ( ស្លឹក និងផ្លែ)
១៤- គ្រសេក ( សំបក)
១៥- ត្រុំ ( ស្លឹក និងផ្លែ)
១៦- ទ្រមែង ( សំបក)
១៧- ទ្រាំង ( ផ្លែ)
១៨- ធ្នង់ ( ឫស)

១៩- ម្ទេញ្ញត្រី ( គ្រាប់)
២០- បាយដំណើប( សំបក)
២១- ប្រាំដំឡឹង( សំបក)
២២- ពិកា ( សំបក និងឫស)
២៣- ព្រហ៊ូតភ្នំ( សំបក)
២៤- ព្រីងថ្ម( សំបក)
២៥- ភ្សៀវ( សំបក)
២៦- រលួសបាយ ( ស្លឹក និងផ្កា)
២៧- រាជព្រឹក្ស ( សំបក)
២៨- លូតស៊ីផ្លែ ( សំបក)
២៩- វល្លិមាស ( ដើម)
៣០- វល្លិចារ ( ជ័រ)
៣១- វល្លិខ្នាញ់
៣២- វល្លិយាវ ( ឫស)
៣៣- វល្លិរមៀត ( ឫស)
៣៤- វល្លិថ្លែន ( សំបក)
៣៥- ស្លែ( សំបក)
៣៦- ស្បែង( សំបក)
៣៧- ស្វាច់ ( សំបក)
៣៨- ស្មៅជ្រលក់ ( ដើម)
៣៩- ស្វាច់ក្រហាម( សំបក)
៤០- ស្លែធំ( សំបក)
៤១- ស្រមី ( សំបក)
៤២- ស្រងល់ ( សំបក)
៤៣- ស្រោកញី( សំបក)
៤៤- ស្វាយ( សំបក)
៤៥- ស្លុំ( សំបក)
៤៦- អង្គ្រង ( សំបក)
៤៧- ឥន្ទជា ( ផ្លែ)
៤៨- សំបក ស្លឹក ផ្កា ផ្លែ ឬរុក្ខជាតិផ្សេងទៀត ។

## IX- រុក្ខជាតិអាហារ មានជាអាទិ៍ :

### ក- អាហារសម្រាប់មនុស្ស

១- កកោះ ( គ្រាប់)
២- កកោះស្បែក( ផ្លែ)
៣- កញ្ចើបាយដាច ( ផ្កា)
៤- កណ្ដោល ( ស្លឹក)
៥- កន្ទ្រោក( ស្លឹក)
៦- កន្ធំថេតព្រៃ ( ស្លឹក និងផ្កា)
៧- កន្ទួងរេស( ផ្លែ)
៨- កន្ទួតព្រៃ( ផ្លែ)
៩- កាណា ( ផ្លែ)
១០- កែស( ផ្លែ)
១១- កំពីងរាជ( ផ្លែ)
១២- កំភ្លាង( ផ្លែ)
១៣- ការទេះ ( ត្រួយ)
១៤- គ្មៀង ( ស្លឹក)
១៥- ក្ដួច ( មើម)
១៦- ក្រាមរមាស( ផ្លែ)
១៧- ក្រចាប់ ( ផ្លែ)
១៨- ក្រចកអណ្ដើក( ផ្លែ)
១៩- ក្រកោស្បាត ( គ្រាប់)
២០- ក្រឡាញ់ ( ផ្លែ)
២១- ក្រឡាំពែ( ដើម)
២២- ក្រសាំង( ផ្លែ)
២៣- ក្រូចព្រៃ( ផ្លែ)
២៤- ក្រវាញ ( ស្លឹក មើម និង គ្រាប់)
២៥- ក្រខុបព្រែក ( ផ្លែ)
២៦- ខោសជ្រូក( ផ្លែ)
២៧- ខោសភ្នំ( ផ្លែ)
២៨- ខោសបាយក្រៀម ( ផ្លែ)

២៩- ខ្នារបន្លា (ផ្លែ)
៣០- គម និងផ្លែល្មើរព្រៃ
៣១- គមចាក
៣២- គមសោម
៣៣- គមផ្កាវ
៣៤- គមស្វាខ្មៅ
៣៥- គុយ (ផ្លែ)
៣៦- គូលែនព្រៃ (ផ្លែ)
៣៧- គ្រាប់វល្លិខ្នើត
៣៨- ចង្រ្កង់ស្វា (ស្លឹក និងផ្កា)
៣៩- ចង្រ្កង់ស្វាធំ (ផ្កា)
៤០- ចង្រ្កង់ស្វាតូច (ផ្កា)
៤១- ចាក់ក្រលឹក
៤២- ចាន់សមុទ្រ (ផ្លែ)
៤៣- ចេកសំពោច (ផ្លែ)
៤៤- ចេកទុំ (សំបក)
៤៥- ច្រេស (ស្លឹក)
៤៦- ឆ្លាល់មាន់ (ស្លឹក)
៤៧- ជង្គង់ប្រើស (ស្លឹក និងដើម)
៤៨- ជង្គង់អណ្តើក (ផ្លែ)
៤៩- ជន្លួស (ផ្លែ)
៥០- ជើងបង្គង (ស្លឹក និងមែកខ្ចី)
៥១- ជើងចាប
៥២- ជើងចាបធំ (ផ្លែ)
៥៣- ជើងគោ (ផ្កា និង ស្លឹក)
៥៤- ជំពូព្រៃ (ផ្លែ)
៥៥- ឈើអែម (សំបក)
៥៦- ឈើត្បាល់ (ផ្លែ)
៥៧- ញ (ស្លឹក)
៥៨- ញព្រៃ (ឫស)
៥៩- ដកចាន់ (ផ្លែ)
៦០- ដកដាវ (ស្លឹក)
៦១- ដីសព្រៃ (មើម)
៦២- ដីប៊ូ (ផ្លែ)
៦៣- ដូងព្រះ (គម)
៦៤- ដូងស្បាត (ផ្លែ)
៦៥- ដើមប្រមាត់ (ផ្លែ)
៦៦- ដែរហាត់ (ផ្លែ)
៦៧- ដំឡូងជ្រៅ (មើម)
៦៨- ដំឡូងត្រែង (មើម)
៦៩- ដំឡូងជ្រូក (មើម)
៧០- ដំឡូងខ្សា (មើម)
៧១- ដំឡូងផ្កាព្រៃ (មើម)
៧២- ដំឡូងខ្សៀន (មើម)
៧៣- ដំឡូងទឹក (មើម)
៧៤- ត្រប់ទុំ (ត្រួយ)
៧៥- ត្រជិត (ផ្លែ)
៧៦- ទ្រមែង (ផ្លែ)
៧៧- ត្រចុក (ត្រួយ)
៧៨- ត្រមូង (ស្លឹក)
៧៩- ត្រមូច (ផ្លែ)
៨០- ថ្កាន់ (ផ្លែ)
៨១- ថ្កាង (ស្លឹក)
៨២- ថ្នឹង (ស្លឹក និងផ្លែ)
៨៣- ទន្សែ (គម និងផ្លែ)
៨៤- ទន្លាធំ (ផ្កា និងផ្លែ)
៨៥- ទាល់ (ដើម)
៨៦- ទេល (មើម)
៨៧- ទំពាំងបាយជូរព្រៃ (ផ្លែ)
៨៨- ទំពាំងឬស្សីព្រៃ
៨៩- ទំពាំងឬស្សីព្រេច
៩០- ទំពាំងឬស្សីឃ្លៃ
៩១- ទំពាំងឬស្សីរលៀក
៩២- ទ្រាលស្វា (ផ្លែ)

៩៣- ទ្រាលដោះក្របី( ផ្លែ)
៩៤- ទ្រនំបង្កួយ( ផ្លែ)
៩៥- ទ្រនំកំភេម ( ផ្លែ)
៩៦- ធ្មេញត្រី( ផ្លែ)
៩៧- ធ្នូក ( ផ្លែ)
៩៨- បង្គៅ ( ផ្លែ)
៩៩- បង្គៅដី( ផ្លែ)
១០០- បង្គៅស៊ីផ្លែ ( ផ្លែ)
១០១- បង្គៅស្វា ( ស្លឹក និងផ្កា)
១០២- បន្ទាក្បាលយក្ស ( ផ្កា)
១០៣- បាបាត ( ផ្លែ)
១០៤- បាយដំណើប ( ស្លឹក)
១០៥- បាយក្រៀមញី( ផ្លែ)
១០៦- បាយកក ( ផ្លែ)
១០៧- បីសន្ទឹក ( ផ្លែ)
១០៨- ប្រោះស្វា ( ស្លឹក)
១០៩- ប្រង់ព្រៃ ( មើម)
១១០- ប្រង់សមុទ្រ ( មើម)
១១១- ប្រង់ទឹក ( ស្លឹក)
១១២- ប្រិច ( ស្លឹក)
១១៣- ផ្កាចាន់ ( ផ្លែ)
១១៤- ផ្កាភ្នាំពូ
១១៥- ផ្កាទឹកដោះព្រៃ( ផ្លែ)
១១៦- ផ្តៅដំបង( ផ្លែ)
១១៧- ផ្តៅឈ្វាំង( ផ្លែ)
១១៨- ផ្ទី ( ឫស)
១១៩- ផ្លែ ប្រដាក់ ( ផ្លែ)
១២០- ផ្សិតកញ្ចុរ
១២១- ផ្សិតក្លោក
១២២- ផ្សិតក្រមួន
១២៣- ផ្សិតក្រាមរមាស
១២៤- ផ្សិតត្រចៀកកណ្តុរ
១២៥- ផ្សិតបំពក
១២៦- ផ្សិតប្រចាក់
១២៧- ផ្សិតពពេល
១២៨- ផ្សិតរងា
១២៩- ផ្សិតស្នាច់
១៣០- ផ្សិតអាកាសយាន
១៣១- ផ្សិតព្រៃហូបបានផ្សេងទៀត
១៣២- ពភ្លា( ផ្លែ)
១៣៣- ពង្រ ( ផ្លែ)
១៣៤- ពង្រភ្នំ( ផ្លែ)
១៣៥- ពុកឆ្មា( ផ្លែ)
១៣៦- ពួចអូល( ផ្លែ)
១៣៧- ព្រះអន្ទក់ ( ស្លឹក)
១៣៨- ព្រីងបាយ( ផ្លែ)
១៣៩- ព្រីងចន្ទុះ( ផ្លែ)
១៤០- ព្រីងអាចម៍កណ្តុរ( ផ្លែ)
១៤១- ព្រីងស្រទាប់ ( ផ្លែ)
១៤២- ព្រួស( ផ្លែ)
១៤៣- ភ្ញៀវ( ផ្លែ)
១៤៤- ភ្លៅមាន់ ( ឫស)
១៤៥- ភ្លាំង ( ឫស)
១៤៦- ភ្លាំង( ផ្លែ)
១៤៧- ភ្លូងជូរ( ផ្លែ)
១៤៨- ភ្លូធំ( ផ្លែ)
១៤៩- មាក់ប្រាង ( ផ្លែ)
១៥០- មៀនព្រៃ( ផ្លែ)
១៥១- រពាក់ ( ផ្លែ)
១៥២- រយោង ( ស្លឹក)
១៥៣- រំដួលស៊ីផ្លែ ( ផ្លែ)
១៥៤- រំដេងព្រៃ ( មើម)
១៥៥- រាំង ( ស្លឹក)
១៥៦- លិង្គពានរ( ផ្លែ)

១៥៧- លូតជុំភ្នំ( ផ្លែ)
១៥៨- លូតស៊ីផ្លែ ( ផ្លែ)
១៥៩- លំពស់ ( ស្លឹក )
១៦០- លំពស់ដែក( ស្លឹក)
១៦១- លាំងដៃ ( ស្លឹក និងផ្លែ)
១៦២- លាំងសាត( ផ្លែ)
១៦៣- ល្បៀង( ស្លឹក និងផ្កា)
១៦៤- ល្ហុ( អម្ពា) ( ស្លឹក និងផ្លែ)
១៦៥- ល្បៀង ( ផ្លែ)
១៦៦- ល្វេ( ផ្លែ)
១៦៧- ល្ហាព្រៃ( ផ្លែ)
១៦៨- ល្ហាធំ( ផ្លែ)
១៦៩- វល្លិក្រាក ( ផ្លែ)
១៧០- វល្លិក្រអោម( ផ្លែ)
១៧១- វល្លិខ្ចូត ( គ្រាប់)
១៧២- វល្លិទាស់ ( ស្លឹក)
១៧៣- វល្លិប៉ប្រើស ( ត្រួយ)
១៧៤- វល្លិមេកង
១៧៥- វល្លិម្ទេសព្រៃ ( ស្លឹក)
១៧៦- វល្លិសណ្ដា ( ស្លឹក)
១៧៧- សណ្ដាន់ ( ផ្លែ)
១៧៨- សណ្ដាន់ព្រៃ( ផ្លែ)
១៧៩- សណ្ដែកព្រៃ ( គ្រាប់)
១៨០- សណ្ដែកក្ងួ ( គ្រាប់)
១៨១- សម្បុរល្វែង ( សំបក)
១៨២- សម្រង ( ផ្លែ)
១៨៣- សាគូចាម( ផ្លែ)
១៨៤- សាគូភ្នំ ( ស្លឹក ផ្លែ និងមើម)
១៨៥- សិរមាន់ ( ផ្លែ)
១៨៦- សំព័រឈើ ( ស្លឹក និងផ្លែ)
១៨៧- ស្ដៅភ្នំ ( ស្លឹក និងផ្កា)
១៨៨- ស្ដី( ស្លឹក)
១៨៩- ស្អាច់ដី( ផ្លែ)
១៩០- ស្រគំស៊ីផ្លែ( ផ្លែ)
១៩១- ស្រម៉ ( ផ្លែ)
១៩២- ស្លឹកចាពូ
១៩៣- ស្លឹកងប់
១៩៤- ស្វាយព្រៃ( ផ្លែ)
១៩៥- ស្វាយកណ្ដុរ ( ស្លឹក និងផ្លែ)
១៩៦- ស្វាយមាស( ផ្លែ)
១៩៧- ហៃសាន ( ស្លឹក និងផ្កា)
១៩៨- អង្កោលបន្លា ( ផ្លែ)
១៩៩- អង្កាញ់ ( ស្លឹក ផ្កា និងផ្លែ)
២០០- អង្គញ់ស្វា ( ផ្កា និង ផ្លែ)
២០១- អង្រ្កង( ផ្លែ)
២០២- អញ្ចាញ ( ផ្លែ)
២០៣- សំបក ឬរុក្ខជាតិផ្សេងទៀតដែលផ្ដល់អនុផលបែបនេះ ។

**ខ- អាហារសម្រាប់បសុសត្វ**

១- ស្មៅផ្កាថ្ម
២- ដំឡូងជ្រូក
៣- ញស្បាត
៤- ឫស្សីឃ្លៃ
៥- ស្មៅកំភេម
៦- ត្រុំព្រៃ
៧- ស្បូវ
៨- ស្មៅចំណីសត្វ
៩- ស្អាច់ទឹក
១០- ឫស្សីព្រេច
១១- សណ្ដែកក្ងួ
១២- ស្មៅអំបុក
១៣- បង្គី
១៤- អនុផលអាហារសំរាប់បសុសត្វផ្សេងទៀត

x — ក្រុមពិសេស មានជាអាទិ៍ :

១- កក្រោក
២- កញ្ជ្រាសភ្លង
៣- កំភ្លឹង
៤- ក្អែក
៥- ក្រាយក្រហម
៦- ក្រាយស
៧- ក្របៅផ្ទៃធំ
៨- ក្រវ៉ាន់
៩- ខ្ទីង
១០- ខ្វារបន្ទា
១១- ត្នូទស្លា
១២- គោល
១៣- ចំប៉ា ស
១៤- ចំប៉ាលឿង
១៥- ចំរៀក
១៦- ច្រេស
១៧- ច្រនៀង
១៨- ច្រនៀងទឹក
១៩- ច្រត់ឥសី
២០- ជើងគោ
២១- ជើងបង្កង
២២- ជ្រៃកៅស៊ូ
២៣- ជ្រៃស
២៤- ជ្រៃសមុទ្រ
២៥- ឈូករត្នព្រៃ
២៦- ឈើ ស
២៧- ដកទឹម
២៨- ដើមកូត
២៩- ដង្អិត
៣០- ដើមប្រង់
៣១- ដើមចារ
៣២- តែព្រៃ
៣៣- ត្រាង
៣៤- ត្របែកព្រៃ
៣៥- ថ្កុល
៣៦- ថ្កូវ
៣៧- ថ្នើមទឹក
៣៨- ទន្លា
៣៩- ទាល់ធំ
៤០- ទ្រមែង
៤១- រល្វីក្រព័ទ្ធឈ្នាង
៤២- រល្វីចេកទុំ
៤៣- រល្វីត្លើក
៤៤- រល្វីប្រាក់កាក់
៤៥- រល្វីមៀន
៤៦- នួនស្រី
៤៧- បង្គោដីរ
៤៨- បាយក្តាំងធំ
៤៩- ប៉ាងកាចាត់
៥០- បូព្រឹក្ស
៥១- បូសនាគ
៥២- បើស
៥៣- បំពង់ស្រមោច
៥៤- ប្រំមោញស្វា
៥៥- ប្រទាលបាយដំណើប
៥៦- ប្រទាលព្រៃគ្រប់ប្រភេទ
៥៧- បំប្រក
៥៨- ផ្កាចាន់ព្រៃ
៥៩- ផ្កាឈាមអន្ទង់
៦០- ផ្កាក្រចក
៦១- ផ្តុំក្រហម
៦២- ផ្តុំស

៦៣- ផ្កាម្លូលពេជ្រ
៦៤- ផ្កាអាចម៍កណ្ដុរ
៦៥- ពួចជូរ
៦៦- ព្រំបន្លា
៦៧- ភ្លៅ
៦៨- ម្រេញ
៦៩- ម្ទេសព្រៃ
៧០- រការ
៧១- រន្ទះបាញ់
៧២- រលួសបាយ
៧៣- រាជព្រឹក្ស
៧៤- រំដួល
៧៥- សណ្ដាន់ព្រៃ
៧៦- សណ្ដែកគ្លីង្គ
៧៧- ស្បែង
៧៨- ស្មៅកំភេមតូច
៧៩- ស្មៅគ្រប់ប្រភេទ
៨០- ស្រត់
៨១- ស្លាក់
៨២- ស្វាយអន្ទក់
៨៣- ហៃសាន (ចាន់ស)
៨៤- អង្រែដែក
៨៥- អង្កាញ់
៨៦- អង្គារសីល្បិ៍
៨៧- អញ្ចាន
៨៨- អន្ទង់ពោយ
៨៩- អំបែងថ្ងៃ (ន័ត្រូត)
៩០- អួយម៉ូយព្រៃ
៩១- អ័រគីដេព្រៃគ្រប់ប្រភេទ
៩២- ឥន្ទនេល
៩៣- រុក្ខជាតិព្រៃមានតម្លៃ និង ផ្ដល់សោភ័ណ្ឌភាពផ្សេងទៀត

XI - អនុផលឈើចម្លាក់ មានជាអាទិ៍ :

១- ពកឈើប្រណីត
២- គល់ និង ឫស ឈើប្រភេទប្រណីត
៣- ឈើដៃខ្លា
៤- ឈើដងដាវ
៥- ឈើខ្មៅ
៦- ដើមគ្រាប់បែក
៧- ឈើកណ្ដោល
៨- ឈើតាត្រាវ
៩- ពកឈើប្រភេទផ្សេងទៀត
១០- គល់ និង ឫសឈើប្រភេទផ្សេងទៀត
១១- ឈើបាក់ដងធំ
១២- ឈើអាដាង
១៣- ឈើអង្កត់ខ្មៅ
១៤- ឈើម្រះព្រៅភ្នំ
១៥- ឈើទេពីរូ
១៦- ឈើ ឬ អនុផលឈើចម្លាក់គ្រប់ប្រភេទ ។

XII - អនុផលប្រើប្រាស់កែច្នៃដោយសិប្បកម្ម មានជាអាទិ៍ :

១- កញ្ជើ
២- កញ្ជេរ
៣- កញ្ច្រែង
៤- កន្ទ្រក
៥- កាចាំងឈើ
៦- កាជា
៧- កំព្រងគ្រប់ប្រភេទ
៨- គ្រឿងផ្គុំតាវ ខង្គិល រទេះ រនាស់
៩- ប្រវាអុំ
១០- គ្រុះ
១១- ចង្កូតទូក
១២- ចង្កឹះ វែក ស្លាបព្រា សម ធ្វើពីឈើ

១៣- ប្រវាំងបែរ
១៤- ផ្កូក
១៥- ជាល
១៦- ដងកណ្ដៀវ
១៧- ដងកាំបិត
១៨- ដងចប
១៩- ដងញញួរ
២០- ដងប៉ែល
២១- ដងពូថៅ
២២- ដងរនាស់
២៣- តៅ
២៤- ធ្នូឈើ
២៥- នឹមគោ ក្របី
២៦- បង្គី
២៧- ល្អី
២៨- សម្ភារឹមដែលកែច្នៃពីអនុផលព្រៃឈើ ដោយសិប្បកម្ម
២៩- សំបកកេសឈើ
៣០- សំបកធុងឈើ
៣១- ឧបករណ៍ក្មេង និងឧបករណ៍ប្រើប្រាស់ផ្សេងទៀត ដែលកែច្នៃពីអនុផលព្រៃឈើដោយ សិប្បកម្ម ។

XIII- ផលប្រមាញ់នៃសត្វព្រៃគ្រប់ប្រភេទ ដូចបានចែងក្នុងប្រកាសស្ដីពីចំណាត់ថ្នាក់សត្វព្រៃគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ។

XIV- សេវាកម្មគ្រប់ប្រភេទ ដែលប្រើប្រាស់ប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ និង ទេសភាពព្រៃឈើជាមូលដ្ឋានក្នុង ដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ជាអាទិ៍ : ការការពារទប់ទល់នឹងភាពសឹករេច ការលំហែកំសាន្ត ទេសចរណ៍ធម្មជាតិ ការសិក្សាស្រាវជ្រាវ ការថតភាពយន្ត ។ល។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**
**លេខៈ** ០១ **អយក** សរណន

**សារាចរណែនាំ**

**ស្តីពី**

**ការប្រឡងបញ្ចប់វគ្គសិក្សាផ្នែកចំណេះទូទៅ បំពេញវិជ្ជាសាធារណៈ និងឯកជន**

យោង :- ប្រកាសលេខ ២១១ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡាចុះថ្ងៃទី ២៧ មករា ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ

- ប្រកាសលេខ ៧៨ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡាចុះថ្ងៃទី ២២ មករា ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ
- សេចក្តីណែនាំលេខ ៣៣៨១ អយក.មចទ ចុះថ្ងៃទី ២២ វិច្ឆិកា ២០០៤ ស្តីពីការរៀបចំប្រឡងនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសំរាប់ឆ្នាំសិក្សា ២០០៤-២០០៥

នៅឆ្នាំសិក្សា ២០០៤-២០០៥នេះ ពិន្ទុសរុបនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិនៅតែរក្សាយកពិន្ទុប្រចាំឆ្នាំ បូកនឹងពិន្ទុប្រឡងថ្នាក់ជាតិ ។ ដោយឡែកការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ត្រូវយកពិន្ទុប្រចាំថ្នាក់នៃត្រីមាស បូកនឹងពិន្ទុប្រឡងថ្នាក់ជាតិ ។

ដើម្បីអោយការប្រឡងថ្នាក់ជាតិ និងការរៀបចំប្រឡងឆមាសទី១ និងទី២តាមសាលារៀន មានលក្ខណៈល្អប្រសើរ ក្រសួងសូមធ្វើការណែនាំដូចតទៅ :

**I. កាលបរិច្ឆេទប្រឡង :**

**I.1. ប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ :**

- កាលបរិច្ឆេទ : ថ្ងៃទី ១១ កក្កដា ២០០៥
- កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រឡង : ថ្ងៃទី ១៧ កុម្ភៈ ២០០៥ ដល់ថ្ងៃទី ១៥ មីនា ២០០៥។

**I.2. ប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ :**

- កាលបរិច្ឆេទ : ថ្ងៃទី ០៨ សីហា ២០០៥
- កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រឡង : ថ្ងៃទី ១៧ កុម្ភៈ ២០០៥ ដល់ថ្ងៃទី ១៥ មីនា ២០០៥

**II. បេក្ខភាពសិស្ស និងសំនុំលិខិតដាក់ពាក្យប្រឡង :**

**II.1.** សំនុំលិខិតដាក់ពាក្យសុំប្រឡងរបស់បេក្ខជន ត្រូវសរសេរដោយដៃបេក្ខជនផ្ទាល់ (គំរូជូនភ្ជាប់) បិទតែម ៣០០រៀល និងមានភ្ជាប់បង្កាន់ដៃបង់សិទ្ធិសុំប្រឡងដូចខាងក្រោម :

- បេក្ខជនប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ បង់ថ្លៃសិទ្ធិប្រលង ១០០០រៀល ។
- បេក្ខជនប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ បង់ថ្លៃសិទ្ធិប្រលង ១៥០០រៀល ។

**II.2. បេក្ខភាព :**

**ក. បេក្ខភាពប្រឡងសញ្ញាប័ត្រ មធ្យមសិក្សាបឋមភូមិ :**

* សិស្សសាលារៀនចំណេះទូទៅសាធារណៈ និងឯកជន ÷
  - ដែលមានអាយុ១៤ឆ្នាំយ៉ាងតិច។
  - បានរៀនចប់មធ្យមសិក្សាបឋមភូមិ គ្រប់កំរិតថ្នាក់។
  - បានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី៩។
  - បានគោរពត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង សំរាប់គ្រឹះស្ថានមធ្យមសិក្សា។
  - បានត្រូវវាយតំលៃផ្នែកសីលធម៌ប្រចាំឆ្នាំ ចាប់ពីមធ្យមឡើងទៅ។

  អាចដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនបាន។

**ខ. បេក្ខភាពប្រឡងសញ្ញាប័ត្រ មធ្យមសិក្សាទុតិយភូមិ :**

* សិស្សសាលារៀនចំណេះទូទៅសាធារណៈ និងឯកជន ÷
  - មានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ។
  - បានរៀននៅមធ្យមសិក្សាទុតិយភូមិគ្រប់កំរិតថ្នាក់។
  - បានរៀនចប់កម្មវិធីថ្នាក់ទី១២ ។
  - បានគោរពត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង សំរាប់គ្រឹះស្ថានមធ្យមសិក្សា។
  - បានត្រូវវាយតំលៃផ្នែកសីលធម៌ប្រចាំឆ្នាំចាប់ពីមធ្យមឡើងទៅ។

  អាចដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនបាន។

  + **លើកលែងតែ :**
  - សិស្សដែលឈប់ដោយមានច្បាប់ ចាប់ពី៤៥ដងឡើងទៅ។
  - សិស្សដែលឈប់ឥតច្បាប់ និងមានច្បាប់ ចាប់ពី៣០ដងឡើងទៅ។
  - សិស្សដែលឈប់ឥតច្បាប់ ចាប់ពី២០ដងឡើងទៅ។
  - សិស្សដែលគ្មានមធ្យមភាគពិន្ទុឆមាសទី១ រឺឆមាសទី២។

* អតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ អាចដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដែលសាមីខ្លួនបានសុំប្រឡងពីមុន រឺអាចដាក់ពាក្យសុំប្រឡង នៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងផ្សេងទៀត ដោយគ្រាន់តែធ្វើសេចក្តីបញ្ជាក់ពីការប្រឡងធ្លាក់លើពាក្យសុំប្រឡង ពីមន្ទីរអប់រំយុវជន និងកីឡាខេត្ត-ក្រុង ដែលសាមីខ្លួនបានប្រឡងធ្លាក់ពីមុន។
* អតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ អាចដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដែលសាមីខ្លួនបានសុំប្រឡងពីមុន រឺនៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា។

** **កំនត់សំគាល់ :**

* ចំនួនអវត្តមានត្រូវគិតចាប់ពីបវេសនកាល រហូតដល់ថ្ងៃទី ២៣ មិថុនា ២០០៥ សំរាប់សិស្សថ្នាក់ទី ១២ និងថ្ងៃទី ០៤ មិថុនា ២០០៥ សំរាប់សិស្សថ្នាក់ទី ៩។

**II.2. បញ្ជីបេក្ខភាព-បញ្ជីរាយនាមសិស្ស ប្រឡងឆមាសលើកទី១-ទី២ និងតារាងស្រង់ពិន្ទុប្រចាំឆ្នាំ :**

នៅដើមឆ្នាំសិក្សា នាយកវិទ្យាល័យត្រូវផ្ញើបញ្ជីសិស្សថ្នាក់ទី១២ ទៅមន្ទីរអប់រំយុវជន និងកីឡា។ មន្ទីរអប់រំ

យុវជន និងកីឡា ត្រូវវាយបញ្ចូលឈ្មោះសិស្សថ្នាក់ទី១២ដែលទទួលបានពីវិទ្យាល័យនីមួយៗទៅក្នុងកុំព្យូទ័រ។ ក្រោយពីពិនិត្យផ្ទៀងផ្ទាត់ និងកែតម្រូវរួចមន្ទីរត្រូវ ៖

-បោះពុម្ពជាលើកទី១ នូវបញ្ជីរាយនាមសិស្សតាមលំដាប់អក្ខរក្រម តាមបន្ទប់ និងតារាងស្រង់ពិន្ទុប្រឡងឆមាសទី១ តាមបន្ទប់ (ចំនួនបេក្ខជនក្នុងមួយបន្ទប់ត្រូវយកតាមការកំនត់របស់វិទ្យាល័យនីមួយៗ) បញ្ជូនទៅវិទ្យាល័យនីមួយៗយ៉ាងហោចណាស់២សប្តាហ៍មុនថ្ងៃប្រឡងឆមាស។ វិទ្យាល័យនីមួយៗ ក្រោយពីទទួលបានបញ្ជីរាយនាមសិស្សថ្នាក់ទី១២តាមបន្ទប់ ត្រូវថតចំឡងបិទផ្សាយបញ្ជីទាំងនោះអោយសិស្សមើល ដើម្បីពិនិត្យ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ក្រែងមានការខុសឆ្គង។ ក្រោយពីទទួលពត៌មានត្រឡប់មកវិញ នាយកត្រូវធ្វើបញ្ជីកែតម្រូវ (តាមគំរូលេខ ០១ជូនភ្ជាប់) ទៅមន្ទីរអប់រំ យុវជន និងកីឡាវិញ។

-ក្រោយពីបានទទួលបញ្ជីកែតម្រូវពីវិទ្យាល័យ មន្ទីរអប់រំ យុវជន និងកីឡា ត្រូវកែតម្រូវទិន្នន័យក្នុងកុំព្យូទ័រ រួចបោះពុម្ពផ្ញើទៅសាលាវិញ។

<u>សំគាល់</u> : ក្រដាស ទឹកខ្មៅ សំរាប់បោះពុម្ពបញ្ជីឈ្មោះ និងតារាងស្រង់ពិន្ទុ...ជាបន្ទុករបស់សាលា ដោយប្រើប្រាស់ថវិកា PAP3 ក្នុងខ្ទង់សម្ភារៈមូលដ្ឋាន។

-បោះពុម្ពជាលើកទី២នូវបញ្ជីបេក្ខភាព តារាងស្រង់ពន្ទុប្រចាំឆ្នាំ ផ្ញើទៅវិទ្យាល័យនីមួយៗក្រោយពេលប្រឡងឆមាសលើកទី១ពីរសប្តាហ៍ ដើម្បីអោយវិទ្យាល័យនីមួយៗ ធ្វើការផ្ទៀងផ្ទាត់។ ក្នុងការផ្ទៀងផ្ទាត់នោះ វិទ្យាល័យនីមួយៗ ត្រូវយកវិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិធ្វើជាគោល ផ្ទៀងផ្ទាត់ជាមួយសលាកប័ត្រឯកត្តជន និងបញ្ជីបេក្ខភាព។ បើពិនិត្យទៅមានខុសឆ្គង វិទ្យាល័យនីមួយៗ ត្រូវកែដោយប៊ិចក្រហមនៅលើបញ្ជីបេក្ខភាព និងតារាងស្រង់ពិន្ទុប្រចាំឆ្នាំ ព្រមទាំងធ្វើបញ្ជីរាយនាមឈ្មោះសិស្ស ដែលត្រូវកែតម្រូវ (តាមគំរូលេខ០២ជូនភ្ជាប់) ផ្ញើមកការិយាល័យប្រឡង នៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងដោយភ្ជាប់មកជាមួយនូវពាក្យសុំប្រឡងរបស់បេក្ខជនផង អោយបានមុនថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥។

* លោកនាយក_នាយិកាសាលា :

- ត្រូវពិនិត្យសំនុំលិខិតដាក់ពាក្យសុំប្រឡងរបស់សិស្ស ដោយផ្ទៀងផ្ទាត់អោយបានត្រឹមត្រូវនូវ ឈ្មោះថ្ងៃ ខែ ឆ្នាំកំនើត ទីកន្លែងកំនើត ឈ្មោះឪពុកម្តាយរបស់សិស្ស ដែលសរសេរក្នុងពាក្យសុំប្រឡង និងសលាកប័ត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណ។ ពាក្យសុំប្រឡង និងសលាកប័ត្រឯកត្តជនរបស់សិស្ស ត្រូវសរសេរអោយច្បាស់។ ត្រូវណែនាំសិស្សអោយរក្សាទុកហ្វីល្មរូបថត ដែលបានបិទលើសលាកប័ត្រឯកត្តជន ដើម្បីងាយស្រួលក្នុងការសុំធ្វើវិញ្ញាបនប័ត្របណ្តោះអាសន្ន នៅពេលប្រឡងជាប់។
- ត្រូវណែនាំអោយសិស្សសរសេរសំនុំលិខិតដាក់ពាក្យសុំប្រលងដោយខ្លួនឯង ចៀសវាងប្រមូលយកទៅអោយគ្រូទទួលបន្ទុកថ្នាក់ រឺមិត្តភក្តិ រឺអ្នកដទៃសរសេរជំនួស។
- ត្រូវចុះហត្ថលេខា និងបោះត្រាលើសលាកប័ត្រពិន្ទុប្រចាំឆ្នាំ របស់សិស្សថ្នាក់ទី៩ (បេក្ខជនម្នាក់ៗបំពេញជា២ច្បាប់) ដែលសរសេរបំពេញដោយផ្ទាល់ដៃសិស្ស ចៀសវាងការកោសលុប រឺសរសេរត្រួត។ ចំពោះសិស្សថ្នាក់ទី១២ ពុំមានសលាកប័ត្រពិន្ទុប្រចាំឆ្នាំទេ។ បន្ទាប់ពីឈប់ទទួលពាក្យសុំប្រឡង ត្រូវរាប់ចំនួនសិស្សដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងចំនួនសិស្សដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ផ្ញើមកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត_ក្រុងដោយ ៖

• ១ច្បាប់សំរាប់មន្ទីរអប់រំ យុវជន និងកីឡា ដើម្បីវាយឈ្មោះសិស្សបញ្ចូល Diskette តាមវិទ្យាល័យនីមួយៗ រួចមន្ទីរអប់រំយុវជន និងកីឡាខេត្ត_ក្រុងផ្ញើ Diskette នោះ មកនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

អោយបានមុនថ្ងៃទី ០១ មេសា ២០០៥។

១ច្បាប់ សំរាប់ក្រសួង (នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ) ដោយភ្ជាប់វិញ្ញាបនប័ត្របណ្តោះអាសន្ន មធ្យមសិក្សាបឋមភូមិ សម័យប្រឡងត្រឹមឆ្នាំ ២០០២ រឺមុនឆ្នាំ ២០០២ អោយបានមុនថ្ងៃទី ០១ មេសា ២០០៥ ដើម្បីក្រសួងផ្ទៀងផ្ទាត់បេក្ខភាព។

**III. ការកំនត់មណ្ឌលប្រឡង :**

កន្លងមក គ្រឹះស្ថានសិក្សាមួយចំនួននៅតាមខេត្ត_ក្រុងដែលត្រូវបានយកធ្វើជាមណ្ឌលប្រឡង នាយក_នាយិកាសាលាពុំទាន់បានរៀបចំអោយអស់លទ្ធភាព ដើម្បីធានាអោយដំណើរការប្រលងប្រព្រឹត្តទៅបានល្អប្រសើរនៅឡើយ។ ដូចនេះ លោក_លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា ត្រូវជ្រើសរើសយកគ្រឹះស្ថានណា ដែលមានដំបូលពុំធ្លុះធ្លាយ មានរបងព័ទ្ធជុំវិញ មានមាត់ច្រកចេញ ចូល មានសោរចាក់ត្រឹមត្រូវ សំរាប់ធ្វើជាមណ្ឌលប្រឡង និងណែនាំអោយ នាយក_នាយិកាសាលា ដែលសាលារបស់ខ្លួនត្រូវបានជ្រើសរើសធ្វើជាមណ្ឌលប្រឡង សំអាតទីធ្លា អគារ បន្ទប់អនាម័យអោយហើយស្រេចមុនដំនើរការប្រឡង។ បន្ទប់ប្រឡងនីមួយៗ ត្រូវរៀបចំអោយមាន តុ ជើងម៉ាមាំទាំ ដើម្បីអោយបេក្ខជនងាយស្រួលក្នុងការសរសេរកិច្ចការ។ បើតុ ជើងម៉ាពុំមាំទាំ ត្រូវជួសជុល រឺរកជើងម៉ាថ្មីមកប្តូរ។ បន្ទប់ប្រឡងនីមួយៗ ត្រូវអោយមានតុ២៥យ៉ាងតិច (តុសំរាប់សិស្សអង្គុយរៀនធម្មតាពីរនាក់) និង១៣តុយ៉ាងតិច (តុសំរាប់សិស្សអង្គុយរៀនធម្មតាបួននាក់)។

មណ្ឌលប្រឡងនីមួយៗ ត្រូវមានប្រដាប់បំពងសំឡេង ដែលអាចប្រើប្រាស់បាន នៅពេលដំណើរការប្រឡង។ សាលាដែលត្រូវយកធ្វើមណ្ឌលប្រឡងត្រូវរក្សាទុកបុគ្គលិក ២រឺ៣នាក់ ទៅតាមទំហំមណ្ឌលប្រឡង។ បុគ្គលិករក្សាទុកនេះត្រូវជ្រើសរើសអ្នកដែលចេះប្រើប្រាស់ និងរៀបចំប្រដាប់បំពងសំឡេង ហើយឈ្លាសវៃក្នុងការដោះស្រាយកង្វះខាតសំភារៈផ្សេងៗ។ ហាមដាច់ខាត ការលក់ដូរនៅ ក្នុងមណ្ឌលប្រឡង ក្នុងរយៈពេលដំនើរការ ការងារប្រឡង។ ត្រូវផ្ញើកំនត់មណ្ឌលប្រឡង ទៅក្រសួង (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ) អោយបានមុនថ្ងៃទី ០១ មេសា ២០០៥។

**IV. សំណើប្រធានវិញ្ញាសាប្រឡង :**

លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី១២ និងទី៩ ត្រូវផ្ញើសំនើប្រធានវិញ្ញាសាប្រឡង ១វិញ្ញាសាក្នុងមួយមុខវិជ្ជា សំរាប់អ្នកបង្រៀនម្នាក់ ដោយភ្ជាប់អត្រាកំនែមកជាមួយផង ដើម្បីជាទុនសំរាប់ក្រសួងពិចារណា និងជ្រើសរើស។ លោកគ្រូ អ្នកគ្រូដែលជាអ្នកស្នើប្រធានវិញ្ញាសា ត្រូវរក្សាការសំងាត់ និងតំលៃមុខវិជ្ជារបស់ខ្លួន ដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះមុខក្រសួង ។

ផ្នែកខាងលើនៃសំណើប្រធានវិញ្ញាសានីមួយៗ ត្រូវសរសេរតាមគំរូជូនភ្ជាប់។ សំណើប្រធានវិញ្ញាសានីមួយៗត្រូវដាក់ក្នុងស្រោមសំងាត់ ដោយបញ្ជាក់មុខវិជ្ជាលើស្រោមនោះផង។

នាយក_នាយិកាសាលា ត្រូវប្រមូលស្រោមសំណើប្រធានវិញ្ញាសាទាំងអស់ ដាក់ក្នុងស្រោមសំងាត់រួម រួចផ្ញើទៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្ត_ក្រុងអោយបានមុនថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥។

***ចំពោះវិញ្ញាសាដែលត្រូវធ្វើសំណើមានដូចតទៅ :***

ក. <u>**សំរាប់ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សា ទុតិយភូមិ**</u> :

១_ ភាសាខ្មែរ ............... រយៈពេល ១២០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១០០។

២_ គណិតវិទ្យា ............... រយៈពេល ១៥០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១២៥។

៣_ រូបវិទ្យា ............... រយៈពេល ៩០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៧៥។
៤_ គីមី ............... រយៈពេល ៦០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។
៥_ ជីវវិទ្យា ............... រយៈពេល ៦០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។
៦_ ផែនដីវិទ្យា .............. រយៈពេល ៣០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៥។
៧_ ប្រវត្តិវិទ្យា ............... រយៈពេល ៤៥នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣៧។
៨_ ភូមិវិទ្យា ............... រយៈពេល ៤៥នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣៨។
៩_ សីលធម៌_ពលរដ្ឋវិជ្ជា ....... រយៈពេល ៦០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។
១០_ សំនួរទំរង់បិទ ............. រយៈពេល ៦០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។

ខ. <u>សំរាប់ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សា បឋមភូមិ</u> :

១_ ភាសាខ្មែរ ............... រយៈពេល ១២០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១០០។
២_ គណិតវិទ្យា ............... រយៈពេល ១២០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១០០។
៣_ រូបវិទ្យា ............... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣០។
៤_ គីមី ............... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៥_ ជីវវិទ្យា ............... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៦_ ផែនដីវិទ្យា .............. រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៧_ ប្រវត្តិវិទ្យា ............... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៨_ ភូមិវិទ្យា ............... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៩_ សីលធម៌_ពលរដ្ឋវិជ្ជា ....... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣០។
១០_ ភាសាបរទេស ........... រយៈពេល ៤៥នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។

លោក_លោកស្រីប្រធានមន្ទីរអប់រំយុវជន និងកីឡាត្រូវផ្សព្វផ្សាយការណែនាំនេះដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សា ដើម្បីអោយការអនុវត្តមានប្រសិទ្ធភាពខ្ពស់។

**<u>ចំលងជូន</u>** :

_ទីស្តីការគណៈរដ្ឋមន្ត្រី
«ដើម្បីសូមជ្រាបជាពត៌មាន»
_គ្រប់សាលាខេត្ត_ក្រុង
«ដើម្បីជូនជ្រាបជាពត៌មាន»
_គ្រប់អង្គភាពនៃទីស្តីការក្រសួងអយក
«ដើម្បីជាពត៌មាន»
_មន្ទីរអយក គ្រប់ខេត្ត_ក្រុង
«ដើម្បីអនុវត្ត»
- កាលប្បវត្តិ
- ឯកសារ-ធា. មបទ

ភ្នំពេញ ថ្ងៃទី ០១ ខែ មិ.ក ឆ្នាំ ២០០៥
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត កុល ផេង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

**លេខ:** ០៧ **អយក.**សណន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាចំណេះទូទៅ និងបំពេញវិជ្ជា

យោង : - ប្រកាសលេខ ២១១អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡាចុះថ្ងៃទី ២៧ មករា ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ។

- ប្រកាសលេខ ៧៨ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡាចុះថ្ងៃទី ២២ មករា ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ។
- សេចក្តីណែនាំលេខ ៣៣៨១ អយក.សណន របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី ២២ វិច្ឆិកា ២០០៤ ស្តីពីការរៀបចំប្រឡងនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ សំរាប់ឆ្នាំសិក្សា ២០០៤-២០០៥។

ដើម្បីអោយការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិមានលក្ខណៈកាន់តែល្អប្រសើរ ក្រសួងអប់រំ យុវជន និងកីឡាសូមធ្វើការណែនាំដូចតទៅ :

**I- យន្តការសំរាប់រៀបចំការប្រឡង :**

**១_ សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ :**

- ខេត្ត-ក្រុងគ្រប់គ្រងផ្ទាល់ការប្រឡង តែក្រសួងនឹងចាត់មន្ត្រីពីក្រសួង និងនាយក នាយករងគ្រឹះស្ថានមធ្យមសិក្សាទៅធ្វើជាអប្បមាទ ក្នុងមួយមណ្ឌលសំនេរមួយនាក់។
- ក្រសួងជាអ្នករៀបចំប្រធានវិញ្ញាសាប្រឡង។
- សមាសភាពនៃគ្រប់គណៈមេប្រយោគ សុទ្ធតែជាមន្ត្រីអប់រំនៅក្នុងខេត្ត-ក្រុង គ្រាន់តែធ្វើការផ្លាស់ប្តូរមេប្រយោគពីស្រុកមួយទៅស្រុកមួយទៀតដែលនៅជិតៗគ្នា ក្នុងខេត្ត-ក្រុង។
- មេប្រយោគទូទាំងប្រទេស មានភារកិច្ចចុះត្រួតពិនិត្យការអនុវត្ត ការងារប្រលងតាមខេត្ត-ក្រុងនីមួយៗ។

**២_សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ :**

- ក្រសួងគ្រប់គ្រងការប្រឡង និងរៀបចំប្រធានវិញ្ញាសាប្រឡង។
- សមាសភាពគណៈកម្មការកណ្តាលគឺជ្រើសរើសមន្ត្រីអប់រំក្នុងខេត្ត-ក្រុង ដោយពុំចាំបាច់ធ្វើការផ្លាស់ប្តូខេត្ត-ក្រុងទេ។
- សមាសភាពគណៈកម្មការអនុរក្ស យកគ្រូថ្នាក់ទី១២ មុខវិជ្ជាប្រឡង ដោយធ្វើការផ្លាស់ប្តូរពី ខេត្ត-

ក្រុងមួយ ទៅខេត្ត-ក្រុងមួយទៀត។ ឯគ្រូថ្នាក់ទី១២ មិនមែនមុខវិជ្ជាប្រឡង គ្រូថ្នាក់ទី១១ រឺថ្នាក់ទី១០ មិនបាច់ផ្លាស់ប្តូរខេត្ត-ក្រុងទេ។

- ប្រធាន-អនុប្រធានមណ្ឌល អប្បមាទ និងគណៈកម្មការត្រួតពិនិត្យតាមអគារ ធ្វើការផ្លាស់ប្តូរពីខេត្ត-ក្រុងមួយ ទៅខេត្ត-ក្រុងមួយទៀត។
- គណៈកម្មការកំនែជាគ្រូបង្រៀនថ្នាក់ទី១២ (មុខវិជ្ជាប្រឡង)នៃគ្រប់វិទ្យាល័យ (ដែលមានអតីតភាពការងារច្រើនជាង៣ឆ្នាំ) និងអធិការមធ្យមសិក្សាដែលពុំមែនជាថ្នាក់ការិយាល័យ ក្នុងឆ្នាំសិក្សា ២០០៤_២០០៥។ ចំពោះគណៈកម្មការកំនែសំនួរទំរង់បិទ ត្រូវយកគ្រូថ្នាក់ទី១២ បង្រៀនគ្រប់មុខវិជ្ជាប្រឡង (ដែលមានអតីតភាពការងារយ៉ាងច្រើន៣ឆ្នាំ) និងគ្រូបង្រៀនភាសាបរទេសថ្នាក់ទី១២ និងអធិការមធ្យមភាសាបរទេស។ ក្នុងករណីការរៀបចំគណៈកម្មការកំនែសំនួរទំរង់បិទពុំគ្រប់ចំនួនអាចជ្រើសរើសយកគ្រូបង្រៀនមុខវិជ្ជាប្រឡងថ្នាក់ទី១១ (ដែលមានអតីតភាពការងារច្រើនជាង៥ឆ្នាំ) មកបំពេញបន្ថែម។ គណៈកម្មការកំនែត្រូវមកបំពេញការងារនៅមណ្ឌលកំនែប្រមូលផ្តុំនៅភ្នំពេញ។
- ពុំមានបង្កើតគណៈកម្មការស្រង់ ឬកពិន្ទុ និងចុះជាប់ធ្លាក់ទេ។ ក្រសួងនឹងបង្កើតគណៈកម្មការមួយសំរាប់ស្រង់ ឬកពិន្ទុដោយកុំព្យូទ័រ គណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល។
- គណៈកម្មការនានាសំរាប់ដំនើរការប្រឡង រៀបចំដូចការប្រលងនាឆ្នាំកន្លងមក គ្រាន់តែមុនពេលដំនើរការប្រឡង ខេត្ត-ក្រុងនីមួយៗត្រូវបង្កើតគណៈកម្មការសំរាប់ធ្វើលិខិតឧទ្ទេសនាម (តាមគំរូ និងនិយាមដូច មានជូនភ្ជាប់)។

## II- ដំណើរការប្រព្រឹត្តទៅនៃការប្រឡង :

### ១_សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ : ( ដំនើរការវិញ្ញាសាសរសេរពីរថ្ងៃ )

- ថ្ងៃទី ១ (ថ្ងៃទី០៧ កក្កដា ២០០៥) : ពេលរសៀល : ប្រជុំគណៈមេប្រយោគទូទាំងប្រទេស និងទូទាំងខេត្ត_ក្រុងនៅភ្នំពេញ។
- ថ្ងៃទី ២ (ថ្ងៃទី០៨ កក្កដា ២០០៥) : គណៈមេប្រយោគទូទាំងខេត្ត_ក្រុង ដឹកប្រធានវិញ្ញាសាទៅកាន់ ខេត្ត_ក្រុងរៀងខ្លួន។
- ថ្ងៃទី ៣ (ថ្ងៃទី០៩ កក្កដា ២០០៥) :

  ពេលព្រឹក : មេប្រយោគទូទាំងខេត្ត_ក្រុងប្រជុំជាមួយប្រធាន_អនុប្រធានមណ្ឌល។

  ពេលរសៀល : ប្រធាន_អនុប្រធានមណ្ឌលដឹកប្រធានវិញ្ញាសា ទៅកាន់មណ្ឌលរបស់ខ្លួន នៅតាមស្រុក។
- ថ្ងៃទី ៤ (ថ្ងៃទី១០ កក្កដា ២០០៥): ពេលរសៀល : ប្រធាន_អនុប្រធានមណ្ឌលប្រជុំជាមួយមេប្រយោគនៅមណ្ឌលរៀងៗខ្លួន។
- ថ្ងៃទី ៥_៦ (ថ្ងៃទី១១_១២ កក្កដា ២០០៥) : **ដំនើរការសរសេរ។**
- ថ្ងៃទី ៧ (ថ្ងៃទី១៣ កក្កដា ២០០៥) : ពេលរសៀល : ប្រជុំមេប្រយោគទូទាំងខេត្ត_ក្រុង ប្រធាន_អនុប្រធានមណ្ឌល និងអប្បមាទស្តាប់របាយការណ៍សំនេរ។
- ថ្ងៃទី ៨-៩ (ថ្ងៃទី១៤-១៥ កក្កដា ២០០៥) : កាត់ក្បាលសន្លឹកកិច្ចការ និងចុះលេខសំងាត់។
- ថ្ងៃទី ១០ (ថ្ងៃទី១៦ កក្កដា ២០០៥): បន្តកាត់ក្បាលសន្លឹកកិច្ចការ និងចុះលេខសំងាត់។

  ពេលព្រឹក : ប្រជុំប្រធាន_អនុប្រធានកំនែធ្វើការណែនាំ និងធ្វើអត្រាកំនែ។

ពេលរសៀល : ប្រធាន_អនុប្រធានកំនែប្រជុំផ្សព្វផ្សាយការណែនាំ និងអគ្រាកំនែជូនដល់សមាជិក។

- ថ្ងៃទី ១១-១២-១៣-១៤ (ថ្ងៃទី១៧-១៨-១៩-២០ កក្កដា ២០០៥) : កែកិច្ចការបេក្ខជន។
- ថ្ងៃទី ១៥_១៦ (ថ្ងៃទី២១_២២ កក្កដា ២០០៥) : ស្រង់ប្អូកពិន្ទុ។
- ថ្ងៃទី ១៧ (ថ្ងៃទី២៣ កក្កដា ២០០៥): គូសជាប់ ធ្លាក់ និងប្រកាសលទ្ធផល។

**២_សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ** : (ដំណើរការវិញ្ញាសាសរសេរពីរថ្ងៃកន្លះ)

- ថ្ងៃទី ១ (ថ្ងៃទី០៤ សីហា ២០០៥) : ពេលរសៀល ប្រជុំគណៈមេប្រយោគទូទាំងប្រទេស នៅភ្នំពេញ។
- ថ្ងៃទី ២ (ថ្ងៃទី០៥ សីហា ២០០៥) : តំនាងមេប្រយោគទូទាំងប្រទេសប្រចាំខេត្ត_ក្រុងដឹកប្រធាន វិញ្ញាសាទៅកាន់ខេត្ត_ក្រុងរៀងៗខ្លួន។
- ថ្ងៃទី ៣ (ថ្ងៃទី០៦ សីហា ២០០៥) : ពេលព្រឹក : មេប្រយោគទូទាំងប្រទេសប្រចាំខេត្ត_ក្រុងប្រជុំជាមួយប្រធាន_អនុប្រធានមណ្ឌល។ ប្រជុំចប់ មេប្រយោគទូទាំងប្រទេសប្រចាំខេត្ត-ក្រុងដឹកប្រធានវិញ្ញាសា នៅតាមស្រុកដែលមានមណ្ឌលប្រលង។
- ថ្ងៃទី ៤ (ថ្ងៃទី០៧ សីហា ២០០៥) : ពេលរសៀល ប្រធាន_អនុប្រធានមណ្ឌលប្រជុំជាមួយមេប្រយោគនៅមណ្ឌលរៀងៗខ្លួន។
- ថ្ងៃទី ៥_៦_៧ (ថ្ងៃទី០៨_០៩_១០ សីហា ២០០៥) : **ដំណើរការសរសេរ។**
- ថ្ងៃទី ៨ (ថ្ងៃទី១១ សីហា ២០០៥) : មេប្រយោគទូទាំងប្រទេសប្រចាំខេត្ត-ក្រុង ដឹកវិញ្ញាសាមកទុកនៅ វិទ្យាល័យព្រះស៊ីសុវត្ថិ។
- ថ្ងៃទី ៩ (ថ្ងៃទី១២ សីហា ២០០៥) : ពេលព្រឹក : ប្រជុំមេប្រយោគទូទាំងប្រទេស ប្រធាន-អនុប្រធានមណ្ឌល និងអប្បមាទស្តាប់របាយការណ៍សំនេរ។
- ថ្ងៃទី ១០ (ថ្ងៃទី១៣ សីហា ២០០៥) :

  ពេលព្រឹក : ដឹកកិច្ចការបេក្ខជនទៅតាមមណ្ឌលកំនែដែលបានបែងចែក និងកាត់ក្បាលសន្លឹកកិច្ចការ និងចុះលេខសំងាត់។

  ពេលរសៀល : កាត់ក្បាលសន្លឹកកិច្ចការ និងចុះលេខសំងាត់។
- ថ្ងៃទី ១១ (ថ្ងៃទី១៤ សីហា ២០០៥) :

  ពេលព្រឹក : ប្រជុំប្រធាន_អនុប្រធានកំនែ និងធ្វើអគ្រាកំនែ។

  ពេលរសៀល : ប្រធាន_អនុប្រធានកំនែប្រជុំផ្សព្វផ្សាយការណែនាំ និងអគ្រាកំនែជូនដល់សមាជិក។
- ថ្ងៃទី១២-១៦ (ថ្ងៃទី១៥-១៦-១៧-១៨-១៩ សីហា ២០០៥) : កែកិច្ចការបេក្ខជន។
- ថ្ងៃទី ១៧ (ថ្ងៃទី២០ សីហា ២០០៥) :

  ពេលព្រឹក : កែកិច្ចការបេក្ខជន។

  ពេលរសៀល : រំសាយគ្រប់គណៈកម្មការមេប្រយោគ។ បង្កើតគណៈកម្មការគ្រប់គ្រងការស្រង់ប្អូកពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការផ្ទៀងផ្ទាត់លទ្ធផល។
- ថ្ងៃទី១៨-២៩ (ថ្ងៃទី២១ សីហា-០១ កញ្ញា ២០០៥) : បញ្ចូលពិន្ទុគ្រប់មុខវិជ្ជាចូលក្នុងកុំព្យូទ័រ។
- ថ្ងៃទី ៣០ (ថ្ងៃទី០២ កញ្ញា ២០០៥) : ប្រកាសលទ្ធផលនៅរាជធានីភ្នំពេញ។

- ថ្ងៃទី ៣១ (ថ្ងៃទី០៣ កញ្ញា ២០០៥) : ប្រកាសលទ្ធផលនៅខេត្ត-ក្រុងនានា។

III- និយាមប្រើប្រាស់មេប្រយោគ :

ការប្រើប្រាស់មេប្រយោគ ជារួមអនុវត្តតាមប្រកាសអន្តរក្រសួង រវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

III.1.សំរាប់ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ :

- មេប្រយោគទូទាំងប្រទេស : * ០១នាក់ សំរាប់ខេត្ត-ក្រុងតូច
  * ០២នាក់ ទៅ ០៥នាក់ សំរាប់ខេត្ត-ក្រុងធំ។
- មេប្រយោគទូទាំងខេត្ត-ក្រុង : ២,៣នាក់ ក្នុង០១មណ្ឌល។
- ប្រធានមណ្ឌល : ០១នាក់ ក្នុង០១មណ្ឌល។
- អនុប្រធានមណ្ឌល : ០១នាក់ ទៅ ០៤នាក់ ក្នុង០១មណ្ឌល។
- អប្បមាទ : ០,១៥នាក់ ក្នុង០១បន្ទប់។
- គណៈកម្មការត្រួតពិនិត្យតាមអាគារ : ០,៧៥នាក់ ក្នុង០១បន្ទប់។
- គណៈកម្មការកណ្តាល : ០,៥នាក់ ក្នុង០១បន្ទប់។
- គណៈកម្មការអនុរក្ស : ២,២៥នាក់ ក្នុង០១បន្ទប់។
- គណៈកម្មការបែងចែកសន្លឹកប្រលង : ៦៥នាក់ ក្នុង០១មណ្ឌលកំនែ។
- គណៈកម្មការកំនែ :* ប្រធាន-អនុប្រធានកំនែ : ០,១នាក់ នៃអ្នកកែ។
  * អ្នកកែ :០,៣នាក់ ក្នុង០១បន្ទប់សំរាប់មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា។
  * អ្នកកែ :០,២នាក់ ក្នុង០១បន្ទប់ សំរាប់មុខវិជ្ជា ក្រៅពីភាសាខ្មែរ និងគណិតវិទ្យា។
- គណៈកម្មការស្រង់ ប្តូរពិន្ទុ និងចុះជាប់ធ្លាក់ : ០,៤នាក់ ក្នុង០១បន្ទប់។
- គណៈកម្មការប្រចាំមណ្ឌលកំនែ : ៣នាក់យ៉ាងច្រើន ក្នុង០១មណ្ឌលកំនែ។
- គណៈកម្មការរៀបចំការប្រឡង : ចំនួន០១នាក់ ក្នុងបេក្ខជន ១៥០០នាក់ និង ០១នាក់បើមានបេក្ខជនពី០១នាក់ ដល់ ១៥០០នាក់។

III.2.សំរាប់ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ :

- មេប្រយោគទូទាំងប្រទេស : * ០២នាក់ សំរាប់ខេត្ត-ក្រុងតូច
  * ០៣នាក់ ទៅ ០៥នាក់ សំរាប់ខេត្ត-ក្រុងធំ។
- ប្រធានមណ្ឌល : ០១នាក់ ក្នុង០១មណ្ឌល។
- អនុប្រធានមណ្ឌល : ០១នាក់ ទៅ ០៤នាក់ ក្នុង០១មណ្ឌល។ (ក្រោម២៥បន្ទប់)
- អប្បមាទ : ០,១៥នាក់ ក្នុង០១បន្ទប់។
- គណៈកម្មការត្រួតពិនិត្យតាមអាគារ : ០,៧៥នាក់ ក្នុង០១បន្ទប់។
- គណៈកម្មការកណ្តាល : ០,៥នាក់ ក្នុង០១បន្ទប់។
- គណៈកម្មការអនុរក្ស : ២,២៥នាក់ ក្នុង០១បន្ទប់។
- គណៈកម្មការកំនែ :* ប្រធាន-អនុប្រធានកំនែ : ០,១៥នាក់ នៃអ្នកកែតាមមុខវិជ្ជា។
  * អ្នកកែ : ០,៣នាក់ ក្នុង០១បន្ទប់សំរាប់មុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា។

* អ្នកកែ : ០,២នាក់ ក្នុង០១បន្ទប់ សំរាប់មុខវិជ្ជាផ្សេងទៀត។

- គណៈកម្មការប្រចាំមណ្ឌលកំនែ : ៥នាក់យ៉ាងច្រើន ក្នុង០១មណ្ឌលកំនែ។
- គណៈកម្មការរៀបចំការប្រឡង :ចំនួន ០១នាក់ ក្នុងបេក្ខជន ៣០០០នាក់ និង ០១នាក់ បើមានបេក្ខជនពី ០១នាក់ ដល់ ៣០០០នាក់។

សំគាល់ : ការគិតចំនួនមេប្រយោគ របស់ខេត្ត-ក្រុងនីមួយៗ អនុវត្តតាមការពន្យល់លំអិតភ្ជាប់ជាមួយគំរូលិខិតឧទ្ទេសនាម គណៈកម្មការនីមួយៗនៃមេប្រយោគប្រឡង។

**IV- ការរៀបចំលិខិតឧទ្ទេសនាមសំរាប់ការប្រឡង :**

មន្ទីរអប់រំ យុវជន និង កីឡាខេត្ត-ក្រុង ត្រូវរៀបចំគណៈកម្មការមួយ សំរាប់ធ្វើពង្រាងលិខិតឧទ្ទេសនាម មេប្រយោគប្រឡង និងបញ្ជីផ្សេងៗតាមការណែនាំដូចតទៅ :

**ក- ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ :**

***១. ពង្រាងលិខិតឧទ្ទេសនាម គណៈមេប្រយោគទូទាំងខេត្ត (គំរូទី១ជូនភ្ជាប់) :***

* សមាសភាពគណៈមេប្រយោគទូទាំងខេត្ត-ក្រុងមាន :

- ប្រធានមន្ទីរអប់រំ យុវជន និងកីឡា .......................................ប្រធាន
- អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា.......................................អនុប្រធាន
- ប្រធាន រឺអនុប្រធានការិយាល័យមធ្យមសិក្សា ការិយាល័យប្រឡង ការិយាល័យអប់រំក្រៅប្រព័ន្ធ ការិយាល័យផែនការ និងគណនេយ្យ និងការិយាល័យមួយចំនួនទៀត នៃមន្ទីរអប់រំ យុវជន និងកីឡា .......................................................សមាជិក
- ប្រធាន រឺអនុប្រធានការិយាល័យអយក.ស្រុក-ខណ្ឌដែលមានមណ្ឌលប្រឡង.......សមាជិក

***២. ពង្រាងលិខិតឧទ្ទេសនាមមេប្រយោគ សំរាប់ដំណើរការវិញ្ញាសាសរសេរ : (គំរូទី២ជូនភ្ជាប់)***

- សមាសភាពប្រធាន-អនុប្រធានមណ្ឌលប្រឡងជ្រើសរើសក្នុងចំនោមនាយក-នាយករងវិទ្យាល័យ អនុវិទ្យាល័យ ដែលមានលក្ខណៈសម្បត្តិល្អ និងឈ្លាសវៃ។
- សមាសភាពគណៈកម្មការកណ្ដាល ជ្រើសរើសក្នុងចំនោមបុគ្គលិកការិយាល័យ នៃវិទ្យាល័យ អនុវិទ្យាល័យ និងបុគ្គលិកនៃមន្ទីរអប់រំ យុវជន និងកីឡា ដែលមានគុណសម្បត្តិល្អ និងមានសមត្ថភាពផ្នែករដ្ឋបាល។
- សមាសភាពគណៈកម្មការអនុរក្ស ជ្រើសរើសក្នុងចំនោមលោកគ្រូ-អ្នកគ្រូបង្រៀនថ្នាក់ទី៧ និងថ្នាក់ទី៨។
- សមាសភាពគណៈកម្មការត្រួតពិនិត្យតាមអាគារ ជ្រើសរើសក្នុងចំនោមនាយករងនៃវិទ្យាល័យ បុគ្គលិកការិយាល័យ នៃមន្ទីរអប់រំ យុវជន និងកីឡា និងបុគ្គលិកការិយាល័យនៃវិទ្យាល័យ អនុវិទ្យាល័យ ដែលសកម្មឈ្លាសវៃ ម៉ត់ចត់នឹងការងារ។

***៣. ពង្រាងលិខិតឧទ្ទេសនាមគណៈកម្មការអប្បមាទ (គំរូទី៣ជូនភ្ជាប់) :***

- សមាសភាពគណៈកម្មការអប្បមាទ ជ្រើសរើសក្នុងចំនោមនាយក នាយករងវិទ្យាល័យ អនុវិទ្យាល័យ និងប្រធាន អនុប្រធានការិយាល័យនៃមន្ទីរអប់រំ យុវជន និងកីឡា ដែលមានបទ ពិសោធន៍ ស្នាដៃល្អ និងឈ្លាសវៃ។

***៤. ពង្រាងលិខិតឧទ្ទេសនាមអ្នកកែតាមមុខវិជ្ជា (គំរូទី៤ជូនភ្ជាប់) :***

* សមាសភាពអ្នកកែតាមមុខវិជ្ជានីមួយៗ គឺជ្រើសរើសក្នុងចំនោមលោកគ្រូ-អ្នកគ្រូដែលបង្រៀនថ្នាក់ទី៩ ។ ក្នុងនោះមាន :
- ប្រធាន-អនុប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជាមួយចំនួន ដែលមានបទពិសោធន៍ និងអតីតភាពយ៉ាងតិច ១០ឆ្នាំ ............................................................ប្រធាន
- ប្រធាន-អនុប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជាមួយចំនួន.....................អនុប្រធាន
- លោកគ្រូ-អ្នកគ្រូតាមមុខវិជ្ជា................................................សមាជិក

***៥. ពង្រាងលិខិតឧទ្ទេសនាមគណៈកម្មការគ្រប់គ្រង និងបែងចែកសន្លឹកកិច្ចការប្រឡង និងគណៈកម្មការស្រង់ពិន្ទុ និងចុះជាប់ធ្លាក់ (គំរូទី៥ជូនភ្ជាប់) :***

- សមាសភាពនៃគណៈកម្មការទាំងនេះ ជ្រើសរើសក្នុងចំនោមបុគ្គលិកការិយាល័យនៃវិទ្យាល័យ អនុវិទ្យាល័យ និងបុគ្គលិកការិយាល័យនៃមន្ទីរអប់រំ យុវជន និងកីឡា ដែលមានគុណសម្បត្តិល្អ (ក្នុងនោះចាប់ពី១២០បន្ទប់ឡើងទៅ ទើបអាចបង្កើតគណៈកម្មការគ្រប់គ្រង និងបែងចែកសន្លឹកកិច្ចការប្រឡង )។
* ចំពោះខេត្ត រតនគិរី-មណ្ឌលគិរី-ស្ទឹងត្រែង-ព្រះវិហារ-កោះកុង -ឧត្តរមានជ័យ-ក្រុងកែប-ក្រុងប៉ៃលិន និងខេត្ត-ក្រុងដែលមានមួយក្រុមមណ្ឌលកំនៃមិនបាច់រៀបចំគណៈកម្មការនេះទេ។

**៦. សំណើប្រធាន_អនុប្រធានមណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (គំរូទី៦ជូនភ្ជាប់) :**

- សមាសភាពប្រធានមណ្ឌល_អនុប្រធានមណ្ឌលប្រឡង ជ្រើសរើសក្នុងចំនោម នាយក នាយករងវិទ្យាល័យ_អនុវិទ្យាល័យដែលមានលក្ខណៈសម្បត្តិល្អ និងឈ្លាសវៃ។

***៧. ពង្រាងលិខិតឧទ្ទេសនាមគណៈកម្មការប្រចាំមណ្ឌលកំនៃ (គំរូទី៧ជូនភ្ជាប់) :***

- សមាសភាពនៃគណៈកម្មការទាំងនេះ ជ្រើសរើសក្នុងចំនោមបុគ្គលិកការិយាល័យ នៃវិទ្យាល័យ អនុវិទ្យាល័យ ដែលត្រូវយកធ្វើជាមណ្ឌលកំនៃ ក្នុងនោះត្រូវមានអ្នកចេះវាយកុំព្យូទ័រ ឬអង្គុលីលេខ អ្នកចេះធ្វើកំនត់ហេតុប្រឡង និងចេះប្រើប្រាស់ប្រដាប់បំពងសំឡេង។

**ខ- ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ :**

***១. លិខិតឧទ្ទេសនាម សំរាប់ដំណើរការវិញ្ញាសាសរសេរ :***

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងគ្រាន់តែរៀបចំវាយឈ្មោះគណៈកម្មការកណ្តាល (គំរូទី៨) និងគណៈកម្មការអនុរក្ស (គំរូទី៩) ដាក់ក្នុង Diskette ប៉ុណ្ណោះ។

* សមាសភាពគណៈកម្មការកណ្តាលជ្រើសរើសចំរុះ ក្នុងចំនោមបុគ្គលិកការិយាល័យនៃមន្ទីរអប់រំ យុវជន និងកីឡា និងបុគ្គលិកការិយាល័យនៃគ្រប់វិទ្យាល័យក្នុងខេត្ត-ក្រុង។ (គំរូទី៨ ជូនភ្ជាប់)
* សមាសភាពអនុរក្ស ជ្រើសរើសក្នុងចំនោមលោកគ្រូ-អ្នកគ្រូថ្នាក់ទី១២ ដែលមិនបង្រៀនមុខវិជ្ជាប្រឡងទាំងអស់ និងលោកគ្រូ អ្នកគ្រូថ្នាក់ទី១១ និងថ្នាក់ទី១០នៃគ្រប់វិទ្យាល័យក្នុងខេត្ត-ក្រុង។ (គំរូទី៩ ជូនភ្ជាប់)

-ខេត្ត-ក្រុងដែលមានតែមួយមណ្ឌលប្រឡង មិនបាច់ធ្វើបញ្ជីឈ្មោះគណៈកម្មការអនុរក្សទេ ព្រោះអនុរក្សនៅខេត្ត-ក្រុងនោះ ជាលោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី១២មកពីខេត្ត-ក្រុងផ្សេង។ តែខេត្តក្រុងនោះ ត្រូវធ្វើបញ្ជីរាយនាមលោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី១២ទាំងអស់ (ទាំងមុខវិជ្ជាប្រឡង និងមុខវិជ្ជាមិនប្រឡង) ផ្ញើមកក្រសួង ដើម្បីក្រសួងប្រើប្រាស់ទៅតាមតំរូវការ។

- ចំពោះខេត្ត-ក្រុងដែលមានចាប់ពីពីរមណ្ឌលឡើងទៅ ត្រូវរៀបចំសមាសភាពអនុរក្ស ជ្រើសរើសក្នុងចំណោមលោកគ្រូ អ្នកគ្រូថ្នាក់ទី១១ និងថ្នាក់ទី១០នៃគ្រប់វិទ្យាល័យក្នុងខេត្ត-ក្រុង ដោយរៀបចំយ៉ាងណា កុំអោយគ្រូ និងសិស្សមានអាគតដ្ឋានដូចគ្នា។ (គំរូទី១០ជូនភ្ជាប់)

***២. ចំពោះការរៀបចំគណៈកម្មការមេប្រយោគផ្សេងទៀត ក្រសួងអប់រំ យុវជន និងកីឡាជាអ្នករៀបចំ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងគ្រាន់តែរៀបចំបន្ថែមនូវ :***

២.១ បញ្ជីរាយនាមប្រធាន-អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ប្រធាន-អនុប្រធានការិយាល័យមធ្យមសិក្សា ការិយាល័យប្រឡង ការិយាល័យអប់រំក្រៅប្រព័ន្ធ ការិយាល័យគណនេយ្យ។ (គំរូទី១១ជូនភ្ជាប់)

២.២ សំនើប្រធាន-អនុប្រធានមណ្ឌល ត្រូវគិតតាមនិយាមដែលបានកំនត់ ដោយគិតធៀប នឹងចំនួនបន្ទប់សរុបក្នុងខេត្ត-ក្រុង។ (គំរូទី១២ជូនភ្ជាប់)

- ប្រធាន-អនុប្រធានមណ្ឌលជ្រើសរើសយកប្រធានការិយាល័យប្រឡង ប្រធានការិយាល័យមធ្យមសិក្សា និងក្នុងចំនោម នាយក-នាយករងវិទ្យាល័យ និងអធិការមធ្យមសិក្សាខេត្ត-ក្រុងទាំងអស់។

២.៣ សំណើអប្បមាទត្រូវគិតតាមនិយាម ០,០៥ ដោយគិតធៀបនឹងចំនួនបន្ទប់សរុបក្នុងខេត្ត-ក្រុង។ (គំរូទី១៣ជូនភ្ជាប់)

- អប្បមាទជ្រើសរើសក្នុងចំនោមប្រធាន-អនុប្រធានការិយាល័យ នៃមន្ទីរអប់រំយុវជន និងកីឡាដែលសកម្មឈ្លាសវៃ។

២.៤ បញ្ជីរាយនាម និងសលាកប័ត្រពត៌មានរបស់គ្រូបង្រៀនថ្នាក់ទី១២តាមមុខវិជ្ជា។ (គំរូទី ១៤ និង ទី១៥ ជូនភ្ជាប់)

២.៥ បញ្ជីរាយនាមអ្នកត្រួតពិនិត្យតាមអគារ។ អ្នកត្រួតពិនិត្យតាមអគារ ជ្រើសរើសក្នុងចំនោម នាយក-នាយករង ប្រធាន-អនុប្រធានក្រុមបច្ចេកទេសថ្នាក់ទី១២ គ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យា ភាសាខ្មែរ និងរូបវិទ្យាថ្នាក់ទី១២តាមនិយាម ០,៧៥ ក្នុងមួយបន្ទប់។ (គំរូទី១៦ជូនភ្ជាប់)

**V- ការផ្ញើសំនុំលិខិត :**

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងត្រូវផ្ញើទៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ អោយបានមុនថ្ងៃទី ០១ មិថុនា ២០០៥ នូវ :

១- ពង្រាងលិខិតឧទ្ទេសនាម គណៈមេប្រយោគទូទាំងខេត្ត (មសបភ)។ (គំរូទី១) និងវាយដាក់ Diskette.។

២- ពង្រាងលិខិតឧទ្ទេសនាម មេប្រយោគ សំរាប់ដំនើរការវិញ្ញាសាសរសេរ (មសបភ)។ (គំរូទី២) និងវាយដាក់ Diskette.។

៣- ពង្រាងលិខិតឧទ្ទេសនាម អប្បមាទ (មសបភ)។ (គំរូទី៣) និងវាយដាក់ Diskette.។

៤- ពង្រាងលិខិតឧទ្ទេសនាម អ្នកកែតាមមុខវិជ្ជា (មសបភ)។ (គំរូទី៤) និងបញ្ចូល Diskette.។

៥- ពង្រាងលិខិតឧទ្ទេសនាម គណៈកម្មការគ្រប់គ្រង និង បែងចែកសន្លឹកកិច្ចការប្រឡង និងគណៈកម្មការស្រង់-បូកពិន្ទុ និងចុះជាប់ធ្លាក់(មសបភ)។ (គំរូទី៥)និងវាយដាក់ Diskette.។

៦- សំនើប្រធាន-អនុប្រធានមណ្ឌលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ (គំរូទី៦) និងបញ្ចូល

Diskette.។

៧- ពង្រាងលិខិតខុទ្ទេសនាម គណៈកម្មការប្រចាំមណ្ឌលកំនែ (មសបក) (គំរូទី៧) និងវាយដាក់ Diskette.។

៨- គណៈកម្មការកណ្តាល (មសទក)។ (គំរូទី៨) និងវាយដាក់ Diskette.។

៩- គណៈកម្មការអនុរក្ស (មសទក)។ (គំរូទី៩) និងវាយដាក់ Diskette.។

១០-បញ្ជីរាយនាមប្រធាន-អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ប្រធាន_អនុប្រធាន ការិយាល័យមធ្យមសិក្សា-ប្រឡង-អប់រំក្រៅប្រព័ន្ធនៃមន្ទីរអប់រំ យុវជន និងកីឡា (មសទក)។ (គំរូទី១០)

១១-សំនើប្រធាន-អនុប្រធានមណ្ឌល (មសទក)។ (គំរូទី១១)

១២-សំនើអប្បមាទពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង (មសទក)។ (គំរូទី១២)

១៣-បញ្ជីរាយនាម និងសលាកប័ត្រពត៌មានរបស់គ្រូបង្រៀនថ្នាក់ទី១២តាមមុខវិជ្ជា (មសទក)។ (គំរូទី១៣ និងទី១៤ ) និងវាយដាក់ Diskette.។

១៤-សំនើអ្នកត្រួតពិនិត្យតាមអាគារ (មសទក)។ (គំរូទី១៥) និងវាយដាក់ Diskette.។

១៥-ស្ថិតិវិទ្យាល័យ-អនុវិទ្យាល័យ (គំរូទី១៦) ។

១៦-បញ្ជីរាយនាមនាយកវិទ្យាល័យ (គំរូទី១៧) ។

១៧-បញ្ជីរាយនាមនាយករងវិទ្យាល័យ (គំរូទី១៨) ។

១៨-បញ្ជីរាយនាមនាយកអនុវិទ្យាល័យ (គំរូទី១៩) ។

១៩-បញ្ជីរាយនាមនាយករងអនុវិទ្យាល័យ (គំរូទី២០) ។

២០-លិខិតខុទ្ទេសនាមគណៈកម្មការធ្វើពង្រាងលិខិតខុទ្ទេសនាម ។ (គំរូទី២១ជូនភ្ជាប់)

**កំនត់សំគាល់** :

រាល់ការបញ្ចូល Diskette ត្រូវអនុវត្តតាមតាមការបណ្តុះបណ្តាលបច្ចេកទេសកុំព្យូទ័រ ពី ថ្ងៃទី ២៦ ដល់ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៥។

វិទ្យាល័យអនុវត្ត ត្រូវបញ្ជូនបញ្ជីឈ្មោះ នាយក នាយករង បុគ្គលិកបង្រៀន និងបុគ្គលិក ការិយាល័យ និងពាក្យសុំប្រឡងរបស់បេក្ខជន ទៅមន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញ។

ក្រសួងសង្ឃឹមថា លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡាគ្រប់ខេត្ត-ក្រុង នឹងខិតខំ អនុវត្តការណែនាំនេះ អោយមានប្រសិទ្ធភាពខ្ពស់។

ភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៥

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

បណ្ឌិត កុល ផេង

<u>**ចំលងជូន**</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "<u>ដើម្បីសូមជ្រាបជាពត៌មាន</u>"
- សាលាខេត្ត-ក្រុង
  "<u>ដើម្បីសូមជ្រាបជាពត៌មាន និង ជួយសហការ</u>"
- គ្រប់អង្គភាពនៃក្រសួងអប់រំ យុវជន និងកីឡា
  "<u>ដើម្បីជាពត៌មាន</u>"
- មន្ទីរ អយក គ្រប់ខេត្ត-ក្រុង
  "<u>ដើម្បីអនុវត្ត</u>"
- កាលប្បវត្តិ
- ឯកសារ ឆា.មទទ

*Circularand Sample for Exam2005 (02) chann14-02.05*